ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រការទូត
# បរិស្ថានកម្ពុជា

ការឆ្លើយតប
នឹងការប្រែប្រួលអាកាសធាតុ

ការអភិរក្ស
ប្រព័ន្ធអេកូឡូស៊ី

កិច្ចគាំពារបរិស្ថាន

ក្រសួងបរិស្ថាន
ឆ្នាំ២០២៦-២០៣០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# យុទ្ធសាស្ត្រការទូត
# បរិស្ថានកម្ពុជា

ឆ្នាំ២០២៦-២០៣០

# បុព្វកថា

ក្នុងបរិការណ៍ដែលពិភពលោកកំពុងប្រឈមមុខនឹងការប្រែប្រួលអាកាសធាតុ និងវិបត្តិបរិស្ថានសកល  ការទូតបរិស្ថានបានក្លាយជាសសរស្តម្ភដ៏សំខាន់មួយនៃគោលនយោបាយការបរទេសរបស់កម្ពុជា។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ខ្ញុំមានសេចក្តីសោមនស្សរីករាយក្នុងការដាក់ចេញនូវ «**យុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា**» ដើម្បីតម្រង់ទិសដៅកម្ពុជាឱ្យក្លាយជាតួអង្គសកម្ម និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចការពារបរិស្ថាន។

ផ្តួចផ្តើមចេញពី **យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១** រាជរដ្ឋាភិបាលបានផ្សារភ្ជាប់យុទ្ធសាស្ត្រការទូតបរិស្ថានជាសសរស្តម្ភដ៏សំខាន់មួយដែលមិនត្រឹមតែផ្តោតលើការការពារធនធានធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែគឺជាឧបករណ៍សេដ្ឋកិច្ចនិងនយោបាយក្រៅប្រទេស ដើម្បីជំរុញការអភិវឌ្ឍប្រកបដោយចីរភាព និងកម្ពុជាក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

សសរស្តម្ភទាំង៥ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ផ្តោតលើការទូតបរិស្ថាននិងលើកកម្ពស់ជាតិ៖**១.ការអភិវឌ្ឍមូលធនមនុស្ស** ក្នុងបរិបទការទូតបរិស្ថានកម្ពុជាដោយផ្តោតលើការបណ្តុះបណ្តាលធនធានមនុស្ស"មន្ត្រីការទូតបៃតង"និងអ្នកជំនាញបច្ចេកទេសដែលមានចំណេះដឹងផ្នែកវិទ្យាសាស្ត្រអាកាសធាតុ មានសមត្ថភាព ចរចាលើឆាកអន្តរជាតិនិងរួមចំណែកដោះស្រាយបញ្ហាបរិស្ថានសកល **២.ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង** នេះជាស្នូលនៃឯករាជ្យភាពសេដ្ឋកិច្ច។ការទូតបរិស្ថានទាក់ទាញឧស្សាហកម្មបៃតងដោយប្រើប្រាស់នូវភាពខ្លាំងផ្នែកថាមពលកកើតឡើងវិញ ដើម្បីទាក់ទាញការវិនិយោគលើវិស័យបច្ចេកវិទ្យា និងការផលិតដែលមិនបំពុលបរិស្ថាន។ លើសពីនោះក៏បើកច្រកសម្រាប់កសិផលបៃតងកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិដែលផ្តល់តម្លៃខ្ពស់ផ្អែកលើបទដ្ឋានបរិស្ថាន **៣.ការអភិវឌ្ឍវិស័យឯកជននិងការងារ** យុទ្ធសាស្ត្រនេះនឹងប្រើប្រាស់ជាផលិតកម្មបៃតង ដើម្បីបង្កើតនូវកាលានុវត្តភាពការងារសម្រាប់ភាពជាដៃគូសាធារណៈនិងឯកជនដោយជំរុញឱ្យក្រុមហ៊ុនអន្តរជាតិសហការជាមួយសហគ្រាសក្នុងស្រុកលើគម្រោងកែច្នៃសំណល់ ឬទេសចរណ៍ធម្មជាតិ ដែលជួយលើកមុខមាត់កម្ពុជាជា

គោលដៅវិនិយោគប្រកបដោយការទទួលខុសត្រូវ **៤.ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន** ជាគោលដៅអាទិភាពនិងជាការលើកកម្ពស់កិត្យានុភាពជាតិលើឆាកអន្តរជាតិ និង **៥. ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ឌីជីថល** បច្ចេកវិទ្យាឌីជីថលត្រូវបានយកមកប្រើក្នុងវិស័យបរិស្ថាន ដូចជា ការគ្រប់គ្រងធនធានតាមឌីជីថលដោយប្រើប្រាស់ប្រព័ន្ធផ្កាយរណបដើម្បីតាមដានការប្រែប្រួលគម្របព្រៃឈើនិងការព្យាករអាកាសធាតុ។ ទំនើបកម្មនេះនឹងលើកតម្កើងកម្ពុជា ជាប្រទេសដែលមានអភិបាលកិច្ចបរិស្ថានឆ្លាតវៃ។

ពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិដោយបន្តកសាងនូវភាពជាដៃគូយុទ្ធសាស្ត្រជាមួយបណ្តាប្រទេសនានា និងអង្គការអន្តរជាតិ ដើម្បីកៀរគរធនធាន និងបច្ចេកវិទ្យាមកបម្រើឱ្យការអភិវឌ្ឍប្រកបដោយចីរភាព។ កម្ពុជាប្តេជ្ញាចិត្តកម្រិតសកលដោយបន្តអនុវត្តតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងការសម្រេចឱ្យបាននូវអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។ ប្រែក្លាយបញ្ហាប្រឈមទៅជាឱកាសសេដ្ឋកិច្ចជំរុញការវិនិយោគលើថាមពលស្អាត ការគ្រប់គ្រងធនធាន ធម្មជាតិប្រកបដោយចីរភាព និងឥណទានកាបូនដែលផ្តល់ផលប្រយោជន៍ដល់សហគមន៍មូលដ្ឋាន។

ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងបរិស្ថាន ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានខិតខំរៀបចំយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ការអនុវត្តយុទ្ធសាស្ត្រនេះដោយឈរលើស្មារតីបុរេសកម្ម កម្ពុជានឹងបន្តឈានទៅមុខយ៉ាងរឹងមាំលើវិថីនៃការអភិវឌ្ឍបៃតងនិងមានភាពធន់។

ថ្ងៃ ខែ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# អារម្ភកថា

ការកសាងលើមូលដ្ឋានគ្រឹះនៃសន្តិភាពនិងស្ថិរភាពនយោបាយ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** កម្ពុជាជាប្រទេសមួយ សម្បូរទៅដោយសម្បត្តិធម្មជាតិដ៏សម្បូរបែប ដែលកំពុងឈរត្រដែតនៅដំណាក់កាលដ៏សំខាន់មួយ ក្នុងដំណើរឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាព។ យើងកត់សម្គាល់ឃើញថា បញ្ហាប្រឈមដែលបង្កឡើងដោយការបំផ្លាញធនធានធម្មជាតិនិងការប្រែប្រួលអាកាសធាតុ បានដើរដល់បន្ទាត់ក្រហម ដែលទាមទារឱ្យមានសកម្មភាពរួម និងត្រូវមានកិច្ចសហការជាយុទ្ធសាស្ត្រ។ អាស្រ័យហេតុនេះហើយទើប **យុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា(យទបក) ឆ្នាំ២០២៦-២០៣០** លេចជារូបរាងឡើង។

**យទបក** មិនត្រឹមតែជាឯកសារយុទ្ធសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែវាជាសក្ខីភាពនៃការប្តេជ្ញាចិត្តដ៏មោះមុតរបស់យើង ក្នុងកិច្ចគាំពារបរិស្ថានសម្រាប់មនុស្សក្នុងពេលបច្ចុប្បន្ន និងអនាគត។ យុទ្ធសាស្ត្រនេះ ក៏ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់យើងក្នុងការចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ ការបង្កើតភាពជាដៃគូ និងការយកចិត្តទុកដាក់លើគោលនយោបាយដែលជំរុញចីរភាពនិងភាពធន់នៃបរិស្ថាន។

កម្ពុជាជាប្រទេសរងគ្រោះពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ត្រូវការវិធីសាស្ត្រគិតគូរឆ្ពោះទៅមុខដ៏រឹងមាំ និងធ្វើឱ្យមានតុល្យភាពនៃកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយនឹងភាពជាម្ចាស់និងអធិបតេយ្យភាពជាតិ។ យើងប្តេជ្ញាប្រើសំឡេងរបស់យើងលើឆាកអន្តរជាតិ ដើម្បីដណ្តើមយកតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍ និងតស៊ូមតិសម្រាប់ដំណោះស្រាយដ៏សមធម៌បំផុត ដើម្បីដោះស្រាយនូវឫសគល់នៃបញ្ហាប្រឈមបរិស្ថាន និងធានានូវអធិបតេយ្យភាពរបស់យើង ក្នុងការកំណត់ផ្លូវអភិវឌ្ឍរបស់យើងផ្ទាល់។

**យទបក** កំណត់នូវអាទិភាពសំខាន់ៗរួមមាន៖

- **ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមរយៈការកាត់បន្ថយ ការបន្សាំ និងអភិបាលកិច្ច** សំដៅដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈ

ការការពារព្រៃឈើ ការផ្លាស់ប្តូរទៅជាថាមពលស្អាត ការលើកកម្ពស់កសិកម្មឈ្លាសវៃនឹងអាកាសធាតុ និងការទាក់ទាញការវិនិយោគបៃតង។ ក្នុងពេលជាមួយគ្នានេះ វាសង្កត់ធ្ងន់ទៅលើការកសាងភាពធន់ តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការត្រៀមលក្ខណៈសហគមន៍ ការពង្រឹងក្របខ័ណ្ឌស្ថាប័ន និងភាពជាដៃគូសាធារណៈនិងឯកជន និងការកៀរគរហិរញ្ញវត្ថុអាកាសធាតុ

- **ការអភិរក្សជីវៈចម្រុះតាមរយៈការការពារធនធានធម្មជាតិ ការស្តារព្រៃឈើឡើងវិញនិងការគាំទ្រជីវភាពរបស់សហគមន៍** សំដៅដល់ការការពារធនធានធម្មជាតិ របស់ប្រទេសកម្ពុជា ដោយការអនុវត្តច្បាប់មុឺងម៉ាត់នៅក្នុងតំបន់ការពារធម្មជាតិ កិច្ចសហការជាមួយភាគីពាក់ព័ន្ធ និងការផ្តល់ធនធានសម្រាប់ការអភិរក្ស។ វាក៏ផ្តោតលើការស្តារព្រៃឈើយ៉ាងសកម្ម តាមរយៈការបង្កើតថ្នាក់បណ្តុះកូនឈើ និងការដាំដើមឈើ ព្រមទាំងការលើកកម្ពស់ជីវភាពសហគមន៍ប្រកបដោយនិរន្តរភាព តាមរយៈទេសចរណ៍ធម្មជាតិ និងការគ្រប់គ្រងធនធានធម្មជាតិ។
- **កិច្ចកាំពារបរិស្ថានតាមរយៈការគ្រប់គ្រងខ្យល់ ទឹក និងសំរាម** សំដៅដល់ការគ្រប់គ្រងការបំពុល តាមរយៈការពង្រឹងបទប្បញ្ញត្តិនិងការអនុវត្តច្បាប់ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ព្រមទាំងការជំរុញថាមពលស្អាតនិងការដឹកជញ្ជូនស្អាត។ វាក៏ផ្តោតលើការកែលម្អអាងប្រព្រឹត្តកម្មទឹកកខ្វក់ ការគ្រប់គ្រងលំហូរទឹកកខ្វក់ពីកសិកម្ម និងការលើកកម្ពស់ការអប់រំសាធារណៈសម្រាប់ការបំពុលទឹក។ លើសពីនេះ វាមានគោលបំណងកែលម្អការគ្រប់គ្រងសំរាម ដោយពង្រឹងប្រព័ន្ធប្រមូលនិងទុកដាក់សំរាម លើកកម្ពស់ការកែច្នៃសំរាមឡើងវិញ និងការអភិវឌ្ឍការកែច្នៃសំរាមឱ្យទៅជាថាមពល។

**យទបក** គូសបញ្ជាក់នូវជំនឿរបស់យើងថា ការទូតបរិស្ថានគឺជាឧបករណ៍សំខាន់មួយ ដែលបានអនុលោមតាមទិសដៅអាទិភាពនៃគោលនយោបាយជាតិ រួមមានក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ យុទ្ធសាស្ត្ររយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន និងយុទ្ធសាស្ត្រចក្រាវិស័យ

បរិស្ថាន។ យើងប្តេជ្ញាចិត្ត ធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូរបស់យើង ទាំងក្នុងនិងក្រៅប្រទេស ដើម្បីកសាងអនាគតកម្ពុជាប្រកបដោយចីរភាព និងភាពធន់បន្ថែមទៀតសម្រាប់ប្រទេសកម្ពុជានិងពិភពលោក។

យើងសូមអញ្ជើញភាគីពាក់ព័ន្ធទាំងអស់ ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់នេះ។ យើងរួបរួមគ្នា យើងអាចនឹងកសាងពិភពលោកមួយ ដែលនិរន្តរភាពបរិស្ថាននិងសុខុមាលភាពសម្រាប់មនុស្សជាតិទូទៅ។

ថ្ងៃ សុក្រ ១កើត ខែ ពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**បណ្ឌិត អ៊ាង សុផល្លែត**

# មាតិកា

ទំព័រ

**បុព្វកថា**.....i

**អារម្ភកថា**.....iii

**មាតិកា**.....vii

**១. សេចក្តីផ្តើម**..... ១

១.១ ទិដ្ឋភាពទូទៅ..... ១

១.២ សមិទ្ធផល..... ៣

១.៣ បញ្ហាប្រឈម ..... ៥

១.៤ កាលានុវត្តភាព ..... ៥

១.៥ ភាពចាំបាច់នៃយុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា ..... ៧

**២. ចក្ខុវិស័យ**..... ៩

**៣. បេសកកម្ម**..... ៩

**៤. គោលបំណងនិងគោលដៅ**..... ៩

**៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ**..... ១០

៥.១ ការវិភាគជាយុទ្ធសាស្ត្រ..... ១០

៥.២ ទិសដៅជាយុទ្ធសាស្ត្រ..... ១០

៥.៣ យុទ្ធសាស្ត្រ ..... ១០

៥.៣.១ យុទ្ធសាស្ត្រទី១៖ ការកសាងសមត្ថភាពការទូតបរិស្ថានក្នុងការដោះស្រាយការបំពុលឆ្លងដែន ..... ១០

៥.៣.២ យុទ្ធសាស្ត្រទី២៖ វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ .. ១១

៥.៣.៣ យុទ្ធសាស្ត្រទី៣៖ ការថែរក្សាប្រព័ន្ធអេកូឡូស៊ី ..... ១៤

៥.៣.៤ យុទ្ធសាស្ត្រទី៤៖ កិច្ចគាំពារបរិស្ថាន ..... ១៦

**៦.សកម្មភាពការងារ**..... ១៨

៦.១ ការកសាងសមត្ថភាពការទូតបរិស្ថាន(ឆ្នាំ២០២៦-២០២៧)..... ១៨

៦.២ ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ(២០២៧-២០២៨)..........១៩
៦.៣ ការថែរក្សាប្រព័ន្ធអេកូឡូស៊ី(២០២៨-២០២៩) ..................................២១
៦.៤. កិច្ចគាំពារបរិស្ថាន(ឆ្នាំ២០២៩-២០៣០)........................................ ២៣
**៧. ធនធានហិរញ្ញវត្ថុ**................................................................................. ២៥
៧.១ ប្រភពថវិកា........................................................................................២៥
៧.២ យន្តការ...............................................................................................២៥
៧.២.១ យន្តការអន្តរក្រសួង..........................................................................២៦
៧.២.២ យន្តការក្រុមការងារ..........................................................................២៨
៧.២.៣ យន្តការថ្នាក់ក្រោមជាតិ.....................................................................៣១
**៨. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ**..............................................................៣៣
៨.១. គោលបំណងនៃក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ..................៣៣
៨.២. យន្តការតាមដានត្រួតពិនិត្យ..........................................................៣៣
៨.៣. យន្តការវាយតម្លៃ............................................................................៣៣
**៩. សន្និដ្ឋាន**.......................................................................................៣៣

# ១. សេចក្តីផ្តើម

## ១.១ ទិដ្ឋភាពទូទៅ

ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលមានព្រំប្រទល់ខាងលិច និងពាយ័ព្យជាប់ប្រទេសថៃ ខាងជើងជាប់ប្រទេសឡាវ និងខាងកើតនិងខាងត្បូងជាប់ប្រទេសវៀតណាម។ រាជធានីភ្នំពេញជាទីក្រុងរស់រវើក ដែលបម្រើជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេស។ ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រដ៏សម្បូរបែប ល្បីល្បាញនាសម័យអាណាចក្រខ្មែរ ដែលមានការរីកចម្រើនពីសតវត្សទី៩ ដល់ទី១៥។ ប្រាសាទបុរាណក្នុងបរិវេណអង្គរវត្ត រួមទាំងប្រាសាទអង្គរវត្ត ត្រូវបានដាក់ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោកដោយអង្គការយូណេស្កូ និងជាតំបន់ទេសចរណ៍ដ៏សំខាន់។ សេដ្ឋកិច្ចកម្ពុជាមានភាពចម្រុះ រួមមានកសិកម្ម ទេសចរណ៍ និងកាត់ដេរ ដែលជាវិស័យសំខាន់។ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ វិស័យទេសចរណ៍មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយសារតំបន់ប្រវត្តិសាស្ត្រ និងសម្រស់ធម្មជាតិរបស់ប្រទេស។ ទេសភាពរួមមានវាលទំនាប ភ្នំ និងទន្លេមេគង្គ ដែលមានសារៈសំខាន់សម្រាប់កសិកម្មនិងការដឹកជញ្ជូន។ បឹងទន្លេសាប គឺជាអច្ឆរិយធម្មជាតិសំខាន់បំផុតរបស់ប្រទេសកម្ពុជា ដែលមានលក្ខណៈភូមិសាស្ត្រដ៏សំខាន់មួយទៀត ដោយគេស្គាល់ថាមានជីវៈចម្រុះសម្បូរបែបជួយទ្រទ្រង់ជីវិត សេដ្ឋកិច្ច និងបរិស្ថានយ៉ាងរឹងមាំ។

កម្ពុជាជាប្រទេសមួយ ក្នុងចំណោមប្រទេសក្នុងតំបន់ ដែលងាយរងគ្រោះខ្លាំងដោយសារអាកាសធាតុ និងប្រឈមមុខនឹងបញ្ហាយ៉ាងខ្លាំងដោយសារការប្រែប្រួលអាកាសធាតុ។ កម្ពុជាមានកំណើនសេដ្ឋកិច្ចគួរឱ្យចាប់អារម្មណ៍ក៏ដោយ ក៏ប្រទេសកម្ពុជាកំពុងជួបប្រទះនឹងការកើនឡើងនៃការបញ្ចេញឧស្ម័ន ពីសកម្មភាពអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះបីជាមានការព្យាករថា ការកើនឡើងសីតុណ្ហភាពពិភពលោកស្ថិតនៅកម្រិតក្រោម ២អង្សារសេ ហើយរាជរដ្ឋាភិបាលកម្ពុជារក្សាបាននូវកម្រិតនៃការវិនិយោគដូចពេលបច្ចុប្បន្នក៏ដោយ ក៏កម្ពុជានឹងជួបប្រទះការខាតបង់ប្រមាណ៩,៨ភាគរយនៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០៥០ ដោយសារការប្រែប្រួលអាកាសធាតុ (MEF, 2019)។ ទោះបីជាមានវិធានការ និងកម្មវិធីបន្ស៊ាំនឹងអាកាសធាតុក៏ដោយ ក៏សហគមន៍និងតំបន់ដែលងាយរងគ្រោះក្នុង

ប្រទេសកម្ពុជា ជួបហានិភ័យនិងផលវិបាកនៃការប្រែប្រួលអាកាសធាតុ ដែលលើសពីអ្វីដែលមនុស្សអាចសម្របខ្លួនបាន ដូចជា ការបាត់បង់ទ្រព្យសម្បត្តិ និងផ្ទះសម្បែងក្នុងអំឡុងពេលទឹកជំនន់ខ្លាំង ជាដើម។ រាជរដ្ឋាភិបាលបានអនុវត្តដំណោះស្រាយការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈគោលនយោបាយ និងយុទ្ធសាស្ត្រសំខាន់ៗពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ កម្ពុជាក៏បានចូលរួមយ៉ាងសកម្មក្នុងកិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងការប្រែ-ប្រួលអាកាសធាតុ ហើយក៏បាននិងបំពេញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងកិច្ចព្រមព្រៀងទី-ក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។

ប្រទេសកម្ពុជាត្រូវបានកំណត់លក្ខណៈថា ជាប្រទេសមានជីវៈចម្រុះសម្បូរបែបប្រព័ន្ធអេកូឡូស៊ីចម្រុះ និងធនធានធម្មជាតិសំខាន់។ វាមានអាកាសធាតុខ្យល់មូសុងត្រូពិចដែលមានរដូវប្រាំងនិងរដូវវស្សា។ ប្រទេសកម្ពុជា មានវាលទំនាបទាប ទន្លេមេគង្គ និងតំបន់ភ្នំ ជាពិសេសនៅភាគពាយ័ព្យ។ វាជាជម្រកនៃប្រព័ន្ធអេកូឡូស៊ីមានជាអាទិ៍ ព្រៃឈើដីសើម និងបរិស្ថានសមុទ្រ ដែលផ្តល់ជម្រកដ៏សំខាន់សម្រាប់សត្វព្រៃ និងធនធានសម្រាប់សហគមន៍មូលដ្ឋាន។ រាជរដ្ឋាភិបាលបានអនុវត្តវិធានការផ្សេងៗតាមរយៈគោលនយោបាយ និងយុទ្ធសាស្ត្រជីវៈចម្រុះ ហើយបានចូលរួមយ៉ាងសកម្មក្នុងការអភិ-រក្សជីវៈចម្រុះអន្តរជាតិ។ សន្និសីទកំពូលបានទទួលស្គាល់ថា ការខិតខំប្រឹងប្រែងរបស់សហគមន៍អន្តរជាតិសម្រាប់ការកាត់បន្ថយកំណើនកម្តៅភពផែនដី នៅមិនទាន់ដល់គោលដៅកំណត់ ១,៥អង្សាសេ នៅឡើយ។ សន្និសីទកំពូលនេះ បានអំពាវនាវ ដល់គ្រប់រដ្ឋភាគីត្រូវរៀបចំនិងដាក់ «ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាស-ធាតុ ដំណាក់កាលទី៣ (NDC 3.0)» របស់ខ្លួនជាបន្ទាន់ ដូចមានចែងនៅក្នុងកិច្ចព្រម-ព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។ លើសពីនេះទៅទៀត ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាផ្នែកមួយដ៏សំខាន់បំផុតនៃវឌ្ឍនភាពនៅក្នុងសន្និសីទកំពូលទីក្រុង Belem ដោយបង្កើតបានក្របខ័ណ្ឌ សូចនាករ សម្រាប់ការតាមដានពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈប្រព័ន្ធមួយច្បាស់លាស់។ ជាមួយគ្នានេះ សេចក្តីសម្រេចបានបញ្ជាក់នូវតម្រូវការចាំបាច់ផ្នែក

ហិរញ្ញវត្ថុសម្រាប់ការបន្សាំដោយបានប្តេជ្ញាចិត្តបង្កើនហិរញ្ញវត្ថុចំនួន៣ដង នៅឆ្នាំ ២០៣៥ ដល់ប្រទេសកំពុងអភិវឌ្ឍ។ កម្ពុជាបានរៀបចំនិងអនុម័តផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជំណាក់កាលទី៣(NDC 3.0) និងយុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា ដើម្បីសម្រេចឱ្យបាននូវឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងចូលរួមជាមួយសហគមន៍អន្តរជាតិ។

## ១.២ សមិទ្ធផល

ប្រទេសកម្ពុជា ប្រកាន់របបរាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ ដែលមានប្រព័ន្ធសភា។ ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋ ចំណែកនាយករដ្ឋមន្ត្រីជាប្រមុខរាជរដ្ឋាភិបាល។ នយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បាននាំមកនូវសុខសន្តិភាព ឯកភាពជាតិ និងបូរណភាពទឹកដី ជូនប្រទេសកម្ពុជា ក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ។ ប្រការនេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល ដែលបាននាំឱ្យសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និងបរិស្ថាន។

នៅក្នុងនីតិកាលទី៧នៃរដ្ឋសភា យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ សម្រាប់ឆ្នាំ២០២៣-២០២៨ គឺជាផែនការអភិវឌ្ឍដ៏ទូលំទូលាយរបស់កម្ពុជា ដែលដាក់ឱ្យប្រើដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃយុទ្ធសាស្ត្រចតុកោណ និងដើរតួជាផែនទីបង្ហាញផ្លូវរបស់រាជរដ្ឋាភិបាលឆ្ពោះទៅការសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព កំណើន សេដ្ឋកិច្ច និងវឌ្ឍនភាព សង្គម។ យុទ្ធសាស្ត្រនេះ ផ្តោតលើសសរស្តម្ភសំខាន់ៗចំនួនប្រាំរួមមាន ពិពិធកម្មសេដ្ឋកិច្ច និងភាពធន់ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនិងទំនើបភាវូបនីយកម្ម និរន្តរភាពបរិស្ថាន និងភាពធន់នឹងអាកាសធាតុ ព្រមទាំងកំណែទម្រង់ស្ថាប័ននិងអភិបាលកិច្ចល្អ សំដៅដោះស្រាយបញ្ហាសំខាន់ៗនៃការអភិវឌ្ឍជាតិ។

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ មុនការរាតត្បាតនៃជំងឺកូវីដ១៩ កម្ពុជាមិនត្រឹមតែសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់៧ភាគរយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរក្សាបាននូវស្ថិរភាពសេដ្ឋកិច្ច តាមរយៈការផ្លាស់ប្តូរ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិផងដែរ។

កំណើនសេដ្ឋកិច្ចជាតិក្រោមម្លប់នៃសន្តិភាព និងគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល បានផ្តល់ឱកាសឱ្យក្រសួងបរិស្ថានបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួនប្រកបដោយវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងវិស័យបរិស្ថាន មានដូចជា ៖

- យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន(២០២៣-២០២៨) ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(២០២៤-២០៣៣) ផែនការយុទ្ធសាស្ត្រកិច្ចគាំពារបរិស្ថាន(២០២៤-២០២៨) យុទ្ធសាស្ត្រជីវៈចម្រុះជាតិនិងផែនការសកម្មភាព យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូនជាដើម ត្រូវបាននិងកំពុងអនុវត្ត
- កិច្ចការផ្សព្វផ្សាយសមិទ្ធផលបរិស្ថានត្រូវបានពង្រឹងនិងពង្រីក
- រដ្ឋបាលឌីជីថល ត្រូវបានរៀបចំឡើងនិងកំពុងត្រូវបានអនុវត្ត
- យុទ្ធនាការ ចលនា ឧបករណ៍ មធ្យោបាយដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធ នឹងការគ្រប់គ្រងសំណល់រឹង សំណល់រាវ និងសំណល់គ្រោះថ្នាក់កំពុងត្រូវបានអនុវត្ត
- តំបន់ការពារធម្មជាតិចំនួន៧០តំបន់ គ្របដណ្តប់លើផ្ទៃដីព្រៃឈើចំនួន៧លាន-ហិកតា ត្រូវបានបង្កើតឡើងនិងកំពុងត្រូវបានការពារយ៉ាងម៉ឺងម៉ាត់
- សហគមន៍តំបន់ការពារធម្មជាតិចំនួន១៩៣សហគមន៍ មានប្រជាពលរដ្ឋចំនួន ៣០២ ៧៣៧នាក់ ត្រូវបានបង្កើតនិងកំពុងដំណើរការ
- ហេដ្ឋារចនាសម្ព័ន្ធនៃគោលបៃតងយ៉ាងតិចចំនួន៧ទីតាំង រួមមាន កោះស្រឡៅ ស្រុកស្រែអំបិល ភ្នំខ្នងផ្សារ ទេទឹកពុះ ភ្នំគិរីរម្យ ភ្នំគូលែន និងតាសាល កំពុងត្រូវបានសាងសង់ សម្រាប់បម្រើសេវាកម្មដល់ទេសចរណ៍ និងគ្រប់គ្រងដោយសហគមន៍ផ្ទាល់។

## ១.៣ បញ្ហាប្រឈម

ទោះបីជាប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពការងារលើវិស័យបរិស្ថាន គួរឱ្យកត់សម្គាល់ក៏ដោយ ក៏វិស័យបរិស្ថានកំពុងជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម ៖

- ឥទ្ធិពលអវិជ្ជមានពីការប្រែប្រួលអាកាសធាតុ រួមមានខ្យល់ព្យុះ ទឹកជំនន់ និងភាពរាំងស្ងួត ចេះតែកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ
- ជីវៈចម្រុះ រួមទាំងព្រៃឈើនិងសត្វព្រៃកំពុងរងការបាត់បង់គួរឱ្យកត់សម្គាល់
- សំរាមសំណល់រឹង រាវ គ្រោះថ្នាក់ មានការកើនឡើង
- ការយល់ដឹងពីលិខិតបទដ្ឋានគតិយុត្តស្តីពីការបំពុលខ្យល់ឆ្លងដែននៅមានកម្រិត។

## ១.៤ កាលានុវត្តភាព

បរិការណ៍សកលនិងនៅក្នុងប្រទេស នាពេលបច្ចុប្បន្នបានផ្តល់ដល់កម្ពុជានូវកាលានុវត្តភាពសំខាន់ៗដូចខាងក្រោម៖

- មូលនិធិអាកាសធាតុបៃតង (Green Climate Fund – GCF) ជាមូលនិធិដែលបានបង្កើតឡើងក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ដែលបានប្តេជ្ញាកៀរគរឱ្យបាន ៣០០ពាន់លានដុល្លារ/ឆ្នាំ ដើម្បីគាំទ្រដល់គម្រោងនានាពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក្នុងប្រទេសកំពុងអភិវឌ្ឍទៅលើផ្នែកការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចល្អ
- មូលនិធិអាកាសធាតុផ្សេងទៀតរួមមាន៖ មូលនិធិបរិស្ថានសកល (GEF) មូលនិធិការបន្សាំ (AF) មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច (LDCF) មូលនិធិការបាត់បង និងការខូចខាត (LDF)។
- មូលនិធិជីវៈចម្រុះគុនមីង (Kunming Biodiversity Fund – KBF) គឺជាមូលនិធិដែលបានបង្កើតឡើងដោយរដ្ឋាភិបាលចិន និងអង្គការ UNEP ដើម្បីគាំទ្រការអនុវត្តគម្រោងនានាពាក់ព័ន្ធនឹងការអភិរក្សជីវៈចម្រុះក្នុងប្រទេសកំពុងអភិវឌ្ឍ

- មូលនិធិក្នុងអនុសញ្ញាអន្តរជាតិនានារួមមានៈ អនុសញ្ញាបាសែល (Basel Convention) អនុសញ្ញារ៉ូតធើដាម (Rotterdam Convention) អនុសញ្ញាស្តុកខូម (Stockholm Convention) ជាដើម ដែលបានបង្កើតឡើង ដើម្បីគាំទ្រដល់គម្រោងនានាពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ក្នុងប្រទេសកំពុងអភិវឌ្ឍ
- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជាពិសេស មុំទី៥ៈ ការធានាចីរភាពបរិស្ថាននិងការរៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតងក្នុងបញ្ចកោណទី៤ៈ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន។ គោលដៅចុងក្រោយ គឺដើម្បីប្រែក្លាយកម្ពុជាជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០
- យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ត្រូវបានបង្កើតឡើងក្នុងគោលបំណងប្រែក្លាយសក្តានុពលនៃវិស័យបរិស្ថានទៅជាឱកាសនិងអត្ថប្រយោជន៍ជាក់ស្តែងសម្រាប់ជាតិ និងប្រជាជនកម្ពុជាគ្រប់ជំនាន់។ វាត្រូវបានតាក់តែងឡើងជារង្វង់ ដោយមានយុទ្ធសាស្ត្រ «ស្នូល» នៅចំកណ្តាលនិងយុទ្ធសាស្ត្រជុំវិញចំនួនបី។ យុទ្ធសាស្ត្រ «ស្នូល» ផ្តោតលើធាតុសំខាន់ចំនួនបី គឺការពង្រឹងគោលនយោបាយកសាងរដ្ឋបាលឌីជីថល និងការពង្រីកការផ្សព្វផ្សាយ។ យុទ្ធសាស្ត្រ «ស្នូល» ដើរតួនាទីជាកម្លាំងបង្វិលយុទ្ធសាស្ត្រចំនួនបីផ្សេងទៀត ឱ្យមានចលនាវិលទៅមុខ។ យុទ្ធសាស្ត្រទីមួយគឺ «ភាពស្អាត» មានមុំបីគឺ ការគ្រប់គ្រងការបំពុល ការធ្វើទំនើបកម្មប្រព័ន្ធវិនិច្ឆ័យការបំពុល និងការលើកកម្ពស់ការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ យុទ្ធសាស្ត្រទីពីរគឺ «ភាពបៃតង» មានមុំបី គឺការពង្រីកចលនាដាំដើមឈើ ការជំរុញការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងការលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។ ជាចុងក្រោយ យុទ្ធសាស្ត្រទីបីគឺ «ចីរភាព» មានមុំបីគឺការធ្វើអនុលោមតាមការពង្រីកកិច្ចសហប្រតិបត្តិការ និងការពង្រឹងការសម្របសម្រួល
- ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលមានស្រាប់ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ កិច្ចគាំពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព។

## ១.៥ ភាពចាំបាច់នៃយុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា

ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក បញ្ហាប្រឈម និងកាលានុវត្តភាពនៃវិស័យបរិស្ថាននៅកម្ពុជា យុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា ត្រូវបានរៀបចំឡើងតាមភាពចាំបាច់ដូចខាងក្រោម៖

- ភាពចាំបាច់ក្នុងការដាក់ចេញនូវ **ជំហរជាយុទ្ធសាស្ត្រក្នុងវិស័យបរិស្ថានកម្ពុជា** សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដែលមានបេសកកម្មចូលរួមក្នុងសន្និសីទ កិច្ចប្រជុំ កិច្ចពិភាក្សា ការចរចាដែលពាក់ព័ន្ធនឹងវិស័យបរិស្ថាន ក្នុងក្របខ័ណ្ឌអន្តរជាតិ
- ភាពចាំបាច់ក្នុងការតម្រង់ទិសដល់មន្ត្រីនៃក្រសួងបរិស្ថានទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យមាន **ជំហររួមក្នុងការអនុវត្តការងារវិស័យបរិស្ថាន** ដោយប្រើប្រាស់អាទិភាពការងារ និងសូចនាករស្របតាមផែនការយុទ្ធសាស្ត្រនិងផែនការ សកម្មភាពនានា របស់អង្គភាពខ្លួន
- ភាពចាំបាច់ក្នុងការពង្រឹងនិងពង្រីកនូវកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីកៀរគរធនធានពីមូលនិធិអន្តរជាតិនានា ឱ្យបានជាអតិបរិមាក្នុងគោលបំណងយកមកអនុវត្តផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ក្រសួងបរិស្ថាន ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**យុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា ឆ្នាំ២០២៦-២០៣០** ត្រូវបានរៀបចំឡើងដោយអនុលោមតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ជាពិសេស មុំទី៥៖ ការធានាចីរភាពបរិស្ថាន និងការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ព្រមទាំងការលើកកម្ពស់សេដ្ឋកិច្ចបៃតង ក្នុងបញ្ចកោណទី៤៖ ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាពនិងបរិយាបន្ន និងស្របតាមយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន (២០២៣-២០២៨) យុទ្ធសាស្ត្ររយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(២០២៤-២០៣៣) ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី៣ យុទ្ធសាស្ត្រជីវៈចម្រុះជាតិនិងផែនការសកម្មភាព(២០១៦-២០៣០) ព្រមទាំងស្របតាមអនុសញ្ញាសហប្រជាជាតិស្តីពី

ការប្រែប្រួលអាកាសធាតុ ជាពិសេសកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្ដីពីការប្រែប្រួលអាកាសធាតុ អនុសញ្ញាសហប្រជាជាតិស្ដីពីជីវៈចម្រុះ ជាពិសេសក្របខ័ណ្ឌជីវៈចម្រុះសកលគូនមីងម៉ុងរ៉េអាល់ និងអនុសញ្ញាអន្តរជាតិផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន មានជាអាទិ៍ អនុសញ្ញាបាសែល (Basel Convention) អនុសញ្ញារ៉ូតជើដាម (Rotterdam Convention) អនុសញ្ញា-ស្តុកខុម (Stockholm Convention) ជាដើម។

កិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កម្ពុជា មានពាក់ព័ន្ធនឹងការគាំទ្រក្នុងការការពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការពហុភាគី អាស៊ាន តំបន់ និងទ្វេភាគី ដោយត្រូវមានតុល្យភាពរវាងតម្រូវការបរិស្ថាន និងជាអាទិភាពនៃអភិវឌ្ឍរបស់កម្ពុជា។

ទិដ្ឋភាពសំខាន់ៗនៃកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កម្ពុជា រួមមាន (១) **ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ៖** កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងកិច្ចខិតខំប្រឹងប្រែងជាសាកលដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុទាំងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យចំនួនប្រាំ រួមមាន ថាមពល ឧស្សាហកម្ម កសិកម្ម ព្រៃឈើ និងសំណល់ ដោយមានគោលបំណងរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់រហូតដល់៥៥ភាគរយនៃការបំភាយឧស្ម័នផ្ទះកញ្ចក់ បើធៀបនឹងការបំភាយក្នុងកម្រិតទូទៅ (BAU) ត្រឹមឆ្នាំ២០៣៥ និងដើម្បីក្លាយជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០ **(២)ការអភិរក្សជីវៈចម្រុះ៖** កម្ពុជាបានប្តេជ្ញាចិត្តចំពោះក្របខ័ណ្ឌជីវៈចម្រុះសកល Kunming-Montreal (GBF) ដែលមានគោលបំណង បញ្ឈប់និងបញ្ច្រាសការបាត់បង់ជីវៈចម្រុះ ត្រឹមឆ្នាំ២០៣០ និងដើម្បីបង្កើតពិភពលោកដែលរស់នៅដោយសុខដុមរមនាជាមួយធម្មជាតិត្រឹមឆ្នាំ២០៥០ និង**(៣)កិច្ចគាំពារបរិស្ថាន៖** កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងវេទិកាអន្តរជាតិ និងការចរចាលើបញ្ហាបរិស្ថាន ព្រមទាំងបានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយ បញ្ហាប្រឈមជាសកល និងជំរុញកិច្ចគាំពារបរិស្ថានដោយផ្ដោតជាសំខាន់លើការគ្រប់គ្រង សំណល់រឹង សំណល់រាវ និងសំណល់គ្រោះថ្នាក់ ដើម្បីរួមចំណែកដល់របៀបវារៈឆ្នាំ២០៣០ សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។

កម្ពុជាកំពុងធ្វើការពង្រឹងក្របខ័ណ្ឌអភិបាលកិច្ចបរិស្ថានរបស់ខ្លួន រួមទាំងការធ្វើទំនើបកម្មក្រសួងបរិស្ថាន និងការពង្រឹងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីកៀរគរធនធានឱ្យបានជាអតិបរិមាពីសហគមន៍អន្តរជាតិ យកមកបម្រើឱ្យវិស័យការពារបរិស្ថាន។ កម្ពុជាក៏បាននិងកំពុងអនុវត្តការងារ ដើម្បីធានាឱ្យបានថា កម្មវិធីនិងគម្រោងបរិស្ថាននានានឹងផ្ដល់អត្ថប្រយោជន៍ផ្ទាល់ទៅដល់សហគមន៍មូលដ្ឋាន លើកកម្ពស់ជីវភាពរស់នៅប្រកបដោយចីរភាព និងផ្ដល់សិទ្ធិអំណាចឱ្យពួកគាត់ចូលរួមយ៉ាងសកម្មក្នុងវិស័យបរិស្ថានជាតិ។

## ២. ចក្ខុវិស័យ

យុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា(យទបក) ធានាចីរភាពបរិស្ថាន រៀបចំខ្លួនឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់សេដ្ឋកិច្ចបៃតង សំដៅប្រែក្លាយកម្ពុជាជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។

## ៣. បេសកកម្ម

ក្រសួងបរិស្ថានមានបេសកកម្មចាត់វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ អភិរក្សជីវៈចម្រុះ គាំពារបរិស្ថាន និងចូលរួមក្នុងការអភិវឌ្ឍប្រកបដោយចីរភាព សម្រាប់ជាផលប្រយោជន៍យូរអង្វែងរបស់ប្រទេសជាតិ និងប្រជាជនកម្ពុជាគ្រប់ជំនាន់ ដោយសហការជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងសហគមន៍អន្តរជាតិទាំងក្នុងក្របខ័ណ្ឌពហុភាគី អាស៊ាន តំបន់ និងទ្វេភាគី។

## ៤. គោលបំណងនិងគោលដៅ

ដើម្បីលើកកម្ពស់មុខមាត់ និងការទទួលខុសត្រូវរបស់ប្រទេសកម្ពុជានៅលើឆាកអន្តរជាតិ ក្នុងការដោះស្រាយបញ្ហាបរិស្ថាន តាមរយៈការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទាក់ទាញជំនួយបច្ចេកទេស និងហិរញ្ញប្បទានបៃតង ដោយសំដៅការពារនិងពង្រឹងភាពធន់នៃប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ តាមរយៈការអនុវត្តច្បាប់ ការស្ដារព្រៃឈើ និងការលើកកម្ពស់ជីវភាពសហគមន៍ប្រកបដោយនិរន្តរភាព ដើម្បីកម្ពុជាឈានទៅសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។

ជាគោលការណ៍ក្រសួងបរិស្ថានធានានូវភាពជាម្ចាស់ ឯករាជ្យ អធិបតេយ្យភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងធនធានហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព រួមទាំងមូលនិធិ បរិស្ថាននិងសង្គម ដើម្បីជំរុញកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ។

# ៥. ក្របខ័ណ្ឌយុទ្ធសាស្ត្រ

## ៥.១ ការវិភាគជាយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រនេះ មិនគ្រាន់តែជាការការពារបរិស្ថាន និងធនធានធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែជា «ការទូតបែបបុរេសកម្ម» ដែលប្រែក្លាយបញ្ហាប្រឈមបរិស្ថាន ការប្រែប្រួលអាកាសធាតុឱ្យទៅជា «កាលានុវត្តភាពសេដ្ឋកិច្ច»។ យុទ្ធសាស្ត្រនេះក៏បានពង្រឹងតួនាទីកម្ពុជាលើឆាកអន្តរជាតិ តាមរយៈការបង្ហាញពីការទទួលខុស-ត្រូវខ្ពស់ចំពោះបញ្ហាសកលលោក។

## ៥.២ ទិសដៅជាយុទ្ធសាស្ត្រ

ពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ លើកកម្ពស់ការអភិរក្សប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ ព្រមទាំងជំរុញការគ្រប់គ្រងបរិស្ថានប្រកបដោយចីរភាព តាម-រយៈការអនុវត្តវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការស្តារព្រៃឈើ ការគ្រប់គ្រងការបំពុល និងការចូលរួមយ៉ាងសកម្មពីសហគមន៍ និងភាគីពាក់ព័ន្ធ ដើម្បីទប់-ស្កាត់ផលប៉ះពាល់អវិជ្ជមាន និងធានាបាននូវអព្យាក្រឹតកាបូននៅឆ្នាំ២០៥០។

## ៥.៣.យុទ្ធសាស្ត្រ

### ៥.៣.១.យុទ្ធសាស្ត្រទី១៖ ការកសាងសមត្ថភាពការទូតបរិស្ថានក្នុងការដោះស្រាយការបំពុលឆ្លងដែន

- **ការកសាងធនធានមនុស្ស៖** ធនធានមនុស្សនៅជាកត្តាដ៏សំខាន់ក្នុងចំណោមអាទិភាពរបស់រាជរដ្ឋាភិបាលដោយផ្តោតលើ មូលធនមនុស្ស ផ្លូវ ទឹក និងភ្លើង។ ការរៀបចំផែនការកសាងធនធានមនុស្ស តាមរយៈការចូលរួមកិច្ចប្រជុំ
- វគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា ការផ្លាស់ប្តូរបទពិសោធនានាជាមួយសហគមន៍អន្តរជាតិ ក៏ដូចជានៅក្នុងកម្រិតជាតិ ដើម្បីពង្រឹងសមត្ថភាពមន្ត្រីឱ្យកាន់តែមានសមត្ថភាពបន្ថែមទៀត។

- **លើកកម្ពស់យន្តការទំនាក់ទំនង៖** ការងារទំនាក់ទំនងអន្តរជាតិជាយន្តការមួយដែលបង្កើតបណ្តាញទំនាក់ទំនងការទូត ការទំនាក់ទំនងទ្វេភាគី និងពហុភាគីត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យក្រសួងស្ថាប័ននីមួយៗ ត្រូវអនុវត្តក្នុងនៃលើកកម្ពស់កិត្យានុភាពជាតិ និងការកៀរគរធនធានសម្រាប់អភិវឌ្ឍប្រទេសជាតិយើងផងដែរ។
- **លើកកម្ពស់ភាពជាដៃគូ(ជាតិនិងអន្តរជាតិ)៖** យុទ្ធសាស្ត្រភាពជាដៃគូសម្រាប់វិស័យនីមួយៗត្រូវពង្រឹង និងពង្រីកភាពជាដៃគូក្នុងនៃពហុភាគី និងទ្វេភាគី។

### ៥.៣.២. យុទ្ធសាស្ត្រទី២៖ វិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

#### ក. ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

- **ការពារនិងពង្រីកគម្របព្រៃឈើ៖** ពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងការកាប់ឈើខុសច្បាប់ និងការទន្ទ្រានយកដី លើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព គាំទ្រការចូលរួមរបស់សហគមន៍ និងអនុវត្តការដាំដើមឈើនិងស្តារព្រៃឈើឡើងវិញ ដើម្បីកាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ និងរេចរឹលព្រៃឈើ បង្កើនសន្និធិកាបូន និងដោះស្រាយឫសគល់បញ្ហានៃការកាប់បំផ្លាញព្រៃឈើ។
- **កាត់បន្ថយឧស្ម័នផ្ទះកញ្ចក់** (GHGs) **ពីវិស័យថាមពល ឧស្សាហកម្ម កសិកម្ម និងសំណល់៖** ផ្លាស់ប្តូរពីការប្រើប្រាស់ឥន្ធនៈហ្វូស៊ីល ដូចជា ធ្យូងថ្ម ប្រេង និងឧស្ម័នធម្មជាតិ មកប្រើប្រាស់ ប្រភពថាមពលស្អាត ដូចជាពន្លឺព្រះអាទិត្យ ខ្យល់ វារីអគ្គិសនី និងប្រភពថាមពលស្អាតផ្សេងទៀត ដែលសមស្របនឹងប្រទេសកម្ពុជា។ អនុវត្តវិធានការកាត់បន្ថយ ការប្រើប្រាស់ថាមពលលើវិស័យផ្សេងៗរួមទាំងការដឹកជញ្ជូន ឧស្សាហកម្ម និងអគារ លំនៅដ្ឋាន។ លើកកម្ពស់ការអនុវត្តកសិកម្មឈ្លាសវៃនឹងអាកាសធាតុ ដើម្បីការពារដំណាំពីការប្រែប្រួលរបបទឹកភ្លៀង គ្រោះរាំងស្ងួត និងទឹកជំនន់ រួមទាំងការប្រើប្រាស់ពូជដំណាំដែលធន់នឹងគ្រោះរាំងស្ងួតនិងទឹក-ជំនន់ ការកែលម្អគុណភាពដី និងការធ្វើពិពិធកម្មកសិកម្ម។ អនុវត្តបច្ចេកវិទ្យាបៃតងនៅក្នុងឧស្សាហកម្ម ដូចជា ស៊ីម៉ងត៍ ដែក និងសារធាតុគីមី ដែលជាអ្នក

បញ្ចេញឧស្ម័នផ្ទះកញ្ចក់សំខាន់ៗ។ កាត់បន្ថយការប្រើប្រាស់សារធាតុរំលាយ ជាពិសេស នៅក្នុងឧស្សាហកម្ម ដូចជា ថ្នាំលាប និងផលិតផលលាងសម្អាត ដែលរួមចំណែកដល់ការបំភាយឧស្ម័នផ្ទះកញ្ចក់។ ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំណល់ ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នមេតានចេញពីទីលានចាក់សំរាមនិងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធគ្រប់គ្រងសំណល់ និងកែច្នៃសំណល់ឡើងវិញ។

- **ទាក់ទាញការវិនិយោគបៃតង៖** បង្កើតបរិយាកាសអំណោយផលដល់ការអនុវត្តអាជីវកម្មប្រកបដោយនិរន្តរភាព(១)ផ្តល់ការលើកទឹកចិត្តសម្រាប់ការវិនិយោគបៃតង ឬការវិនិយោគដែលមានការបំភាយឧស្ម័នទាប ដូចជាការលើកលែងពន្ធ ការកាត់បន្ថយពន្ធនាំចូលសម្រាប់បច្ចេកវិទ្យាបៃតង និងការលើកទឹកចិត្តដល់ឥណទានកាបូន (២)បង្កើនប្រភពថាមពលកកើតឡើងវិញ ដូចជា ថាមពលព្រះអាទិត្យ ខ្យល់ និងវារីអគ្គិសនី ដែលមានសក្តានុពលខ្លាំង ហើយអភិវឌ្ឍគម្រោងខ្នាតធំ ដូចជា សួនថាមពលព្រះអាទិត្យ និងកសិដ្ឋានខ្យល់។ (៣)លើក-ទឹកចិត្តឱ្យអង្គការអន្តរជាតិ ធនាគារអភិវឌ្ឍន៍ និងអ្នកវិនិយោគឯកជន ផ្តល់មូល-និធិដល់គម្រោងបៃតង។

## ខ. ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ

- **អភិវឌ្ឍការត្រៀមខ្លួនផ្ទាល់ខ្លួន និងសកម្មភាពសហគមន៍៖** កែសម្រួលទាំងអាកប្ប-កិរិយាផ្ទាល់ខ្លួន និងការអនុវត្តរបស់សហគមន៍ ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដោយធ្វើបុរេសកម្មក្នុងការកាត់បន្ថយហានិភ័យ ការកាត់បន្ថយភាពងាយរងគ្រោះ និងការធ្វើឱ្យសហគមន៍ អាជីវកម្ម និងបុគ្គលកាន់តែមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ។
- **កសាងហេដ្ឋារចនាសម្ព័ន្ធដែលមានភាពធន់៖** ពង្រឹងការគ្រប់គ្រងធនធានទឹក ជាពិសេស អាងទន្លេមេគង្គ និងបឹងទន្លេសាប តាមរយៈប្រព័ន្ធគ្រប់គ្រងទឹក-ជំនន់ និងការស្តុកទឹកឱ្យកាន់តែប្រសើរឡើងដោយយកចិត្តទុកដាក់ចំពោះការ

តាក់តែងគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងត្រូវគិតអំពីភាពធន់ទៅនឹងអាកាសធាតុ និងដំណោះស្រាយផ្អែកលើធម្មជាតិ។

- **អនុវត្តកសិកម្មដែលធន់នឹងអាកាសធាតុ ៖** លើកកម្ពស់ការអនុវត្តកសិកម្មឈ្លាសវៃនឹងអាកាសធាតុ ដើម្បីការពារដំណាំពីការប្រែប្រួលរបបទឹកភ្លៀង គ្រោះរាំងស្ងួត និងទឹកជំនន់។ ប្រើប្រាស់ពូជដំណាំដែលធន់នឹងគ្រោះរាំងស្ងួតនិងទឹកជំនន់ កែលម្អគុណភាពដី និងធ្វើពិពិធកម្មកសិកម្ម។

គ. អភិបាលកិច្ចល្អ

- **ពង្រឹងក្របខ័ណ្ឌស្ថាប័ននិងគោលនយោបាយ៖** បង្កើតរចនាសម្ព័ន្ធភាពជាអ្នកដឹកនាំច្បាស់លាស់សម្រាប់ការប្រែប្រួលអាកាសធាតុ បញ្ចូលគោលដៅនៃការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍជាតិ និងគោលនយោបាយតាមវិស័យ ធានាឱ្យមានការចូលរួមពីរដ្ឋបាលមូលដ្ឋាន និងសហគមន៍ក្នុងដំណើរការធ្វើការសម្រេចចិត្តអំពីអាកាសធាតុ និងសម្របគោលនយោបាយជាតិ ជាមួយកិច្ចព្រមព្រៀងអាកាសធាតុអន្តរជាតិ។
- **ពង្រឹងភាពជាដៃគូសាធារណៈ និងឯកជន៖** ចូលរួមជាមួយភាគីពាក់ព័ន្ធ រួមទាំងស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងវិស័យឯកជន ក្នុងការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយអាកាសធាតុ។ ធានាឱ្យមានរបាយការណ៍វឌ្ឍនភាពជាប្រចាំដើម្បីកសាងទំនុកចិត្តនិងគណនេយ្យភាពសាធារណៈ។ ពង្រឹងភាពជាដៃគូសាធារណៈ និងឯកជន (PPPs) ដើម្បីកាត់បន្ថយហានិភ័យ និងបង្កើនទំនុកចិត្តរបស់អ្នកវិនិយោគលើវិស័យបៃតងដែលកំពុងរីកចម្រើននៅកម្ពុជា។
- **កៀរគរហិរញ្ញវត្ថុអាកាសធាតុនិងហេដ្ឋារចនាសម្ព័ន្ធមានភាពធន់៖** កៀរគរហិរញ្ញប្បទានអាកាសធាតុទាំងក្នុងស្រុកនិងអន្តរជាតិ ដើម្បីគាំទ្រគម្រោងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ រួមទាំងកសិកម្មប្រកបដោយនិរន្តរភាព ថាមពល កកើតឡើងវិញ និងប្រព័ន្ធគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយភាពងាយរងគ្រោះ និងលើកកម្ពស់ភាពធន់របស់កម្ពុជា ចំពោះផលប៉ះពាល់ដែលបណ្តាលមកពី

ការប្រែប្រួលអាកាសធាតុ។ កសាងសមត្ថភាពលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើម្បីក្លាយជាអង្គភាពមានសម្បទា ក្នុងការទទួលបានហិរញ្ញវត្ថុអាកាសធាតុដោយផ្ទាល់ពីមូលនិធិអន្តរជាតិ ជាពិសេស ពីមូលនិធិ-អាកាសធាតុបៃតង (GCF) និងដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជូនហិរញ្ញវត្ថុអាកាសធាតុ ទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជា ខេត្ត ស្រុក និងឃុំ។

### ៥.៣.៣ យុទ្ធសាស្ត្រទី៣៖ ការថែរក្សាប្រព័ន្ធអេកូឡូស៊ី

#### ក. ការអភិរក្សជីវៈចម្រុះ

- **អនុវត្តច្បាប់ក្នុងតំបន់ការពារ៖** អនុវត្តវិធានការអភិរក្ស ដោយអនុវត្តការអនុវត្តច្បាប់ ១០០ភាគរយ ជាពិសេស អនុលោមតាមក្រមបរិស្ថាននិងធនធានធម្មជាតិ អនុវត្តវិធានការអនុវត្តច្បាប់យ៉ាងតឹងរ៉ឹង និងលុបបំបាត់វប្បធម៌ដោះលែងសកម្មភាពខុសច្បាប់។
- **សហការជាមួយតួអង្គសំខាន់ៗ៖** សហការជាមួយក្រសួងយុត្តិធម៌និងមេធាវីស្ថាប័នជាតិពាក់ព័ន្ធ រួមទាំង គណៈកម្មាធិការជាតិដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសធនធានជាតិ ក៏ដូចជាអង្គភាពប្រឆាំងអំពើពុករលួយ។
- **ជំនួយសម្ភារៈ ឧបករណ៍ និងមធ្យោបាយ៖** ផ្តល់ផែនទីតំបន់ការពារធម្មជាតិរូបភាពផ្កាយរណប និងយន្តហោះគ្មានមនុស្សបើក ក៏ដូចជាសម្ភារៈ និងឧបករណ៍ល្បាតដល់តួអង្គសំខាន់ៗ ដែលអនុវត្តការអនុវត្តច្បាប់នៅក្នុងតំបន់ការពារ។

#### ខ. ការស្តារព្រៃឈើឡើងវិញ

- **បង្កើតថ្នាលបណ្តុះកូនឈើថ្នាក់តំបន់និងខេត្ត៖** បង្កើតថ្នាលបណ្តុះកូនឈើថ្នាក់តំបន់ចំនួន៥ និងថ្នាក់ខេត្តនៅរាជធានី ខេត្ត ដើម្បីចែកកូនឈើធម្មជាតិ និងកូនឈើហូបផ្លែដល់សាធារណជន ដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋដាំបាននៅទីកន្លែងដែលពួកគេចង់ដាំ និងត្រូវការដាំ។
- **ចែកកូនឈើដោយមិនគិតថ្លៃ៖** ចែកកូនឈើទាំងកូនឈើធម្មជាតិ និងកូនឈើហូបផ្លែដោយមិនគិតថ្លៃ ដល់សាធារណជន ពីការតាំងពិពណ៌កូនឈើថ្នាក់ជាតិ

និងខេត្ត និងពីថ្នាលបណ្តុះកូនឈើ ដើម្បីដាំនៅតាមគេហដ្ឋាន សហគមន៍ និងព្រៃរេចរឹល។

- **ដាំដើមឈើ៖** ផ្តោតលើការដាំប្រភេទដើមឈើ និងរុក្ខជាតិដែលសម្របខ្លួនទៅនឹងបរិស្ថានក្នុងតំបន់ ដើម្បីធានាអត្រារស់រានមានជីវិតកាន់តែប្រសើរ និងភាពសមស្របនឹងប្រព័ន្ធអេកូឡូស៊ី។ ផ្តល់អាទិភាពដល់ដើមឈើដែលអាចស្តារឡើងវិញនូវជីវៈចម្រុះ ធ្វើឱ្យប្រសើរឡើងនូវគុណភាពដី និងលើកកម្ពស់សេវាកម្មប្រព័ន្ធអេកូឡូស៊ី ដូចជាការថែរក្សាទឹក និងការស្រូបទុកកាបូន។

គ. ជីវភាពសហគមន៍

- **ជំរុញទេសចរណ៍ធម្មជាតិ៖** បង្កើតគំនិតផ្តួចផ្តើមទេសចរណ៍ធម្មជាតិនៅក្នុងតំបន់ការពារ ដើម្បីលើកកម្ពស់ជីវភាពសហគមន៍។ នេះរួមបញ្ចូល ទាំងការបណ្តុះបណ្តាលប្រជាសហគមន៍ អំពីមគ្គុទ្ទេសក៍ទេសចរ ការគ្រប់គ្រងកន្លែងស្នាក់នៅដែលមានបរិស្ថានល្អ ការផលិតនិងលក់ផលិតផលសិប្បកម្មក្នុងស្រុកដល់ភ្ញៀវទេសចរ ដោយធានាផលប្រយោជន៍ពីទេសចរណ៍ត្រូវបានចែករំលែកនៅក្នុងសហគមន៍។
- **គាំទ្រការគ្រប់គ្រងធនធានធម្មជាតិ៖** លើកទឹកចិត្តដល់ការធ្វើកសិកម្មប្រកបដោយនិរន្តរភាព ការនេសាទ ការចិញ្ចឹមសត្វ និងការប្រើប្រាស់អនុផលព្រៃឈើ ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលដៅអភិរក្ស។ ផ្តល់ការបណ្តុះបណ្តាល និងធនធានដល់សហគមន៍មូលដ្ឋាន លើការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព ដែលការពារជីវៈចម្រុះ ដូចជា ការដកហូតអនុផលព្រៃឈើ (ឧទាហរណ៍ ទឹកឃ្មុំ ផ្សិត ផ្លែឈើ គ្រាប់ គ្រាប់ ចំណី ឫស្សី ផ្តៅ រុក្ខជាតិដែលអាចបរិភោគបាន រុក្ខ-ជាតិឱសថ) ឬវារីវប្បកម្មប្រកបដោយនិរន្តរភាព។
- **ពង្រឹងការចូលរួមរបស់សហគមន៍៖** អនុញ្ញាតឱ្យសហគមន៍មូលដ្ឋានចូលរួមក្នុងដំណើរការគ្រប់គ្រង និងធ្វើសេចក្តីសម្រេចចិត្តនៃតំបន់ការពារធម្មជាតិ។ ផ្តល់សិទ្ធិអំណាចដល់សហគមន៍ក្នុងការធ្វើផែនការ ការអនុវត្ត និងការត្រួតពិនិត្យសកម្មភាពអភិរក្សរបស់ពួកគេក្នុងភាពជាម្ចាស់ និងធានាថាយុទ្ធសាស្ត្រអភិរក្ស

គាំទ្រទាំងសុខភាពនៃប្រព័ន្ធអេកូឡូស៊ី និងសុខុមាលភាពសហគមន៍នៅក្នុងសេដ្ឋកិច្ចមូលដ្ឋាន។

### ៥.៣.៤ យុទ្ធសាស្ត្រទី៤៖ កិច្ចគាំពារបរិស្ថាន

#### ក. ការបំពុលខ្យល់

- **ពង្រឹងបទប្បញ្ញត្តិគុណភាពខ្យល់និងការអនុវត្តច្បាប់៖** អនុវត្តតាមស្តង់ដា និងបទប្បញ្ញត្តិគុណភាពខ្យល់យ៉ាងតឹងរ៉ឹងសម្រាប់ឧស្សាហកម្ម យានជំនិះ និងសកម្មភាពសំណង់។ ពង្រឹងប្រព័ន្ធត្រួតពិនិត្យ ដើម្បីតាមដានកម្រិតបំពុល និងរៀបចំឱ្យអ្នកបំពុលទទួលខុសត្រូវ។
- **លើកកម្ពស់ការយល់ដឹងនិងសកម្មភាព៖** លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីផលប៉ះពាល់សុខភាពនៃការបំពុលបរិយាកាស និងការលើកកម្ពស់អាកប្បកិរិយាដែលកាត់បន្ថយការបំពុល ដូចជា កាត់បន្ថយការប្រើប្រាស់យានយន្ត ជៀសវាងការដុតសំរាម ការដុតវាលស្រែ និងការអនុវត្តការចម្អិនអាហារស្អាត។ លើកទឹកចិត្តឱ្យមានការចូលរួមពីសហគមន៍ក្នុងកិច្ចខិតខំប្រឹងប្រែងកែលម្អគុណភាពខ្យល់។
- **លើកកម្ពស់ថាមពលស្អាតនិងការដឹកជញ្ជូន៖** ផ្លាស់ប្តូរឆ្ពោះទៅរកប្រភពថាមពលកកើតឡើងវិញ (ដូចជាពន្លឺព្រះអាទិត្យ និងខ្យល់) និងលើកទឹកចិត្តឱ្យប្រើប្រាស់យានជំនិះអគ្គិសនី ការដឹកជញ្ជូនសាធារណៈ និងឥន្ធនៈស្អាត ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពីការផលិតថាមពល និងការដឹកជញ្ជូន។

#### ខ. ការបំពុលទឹក

- **ពង្រឹងការគ្រប់គ្រងនិងប្រព្រឹត្តកម្មទឹកកខ្វក់៖** កែលម្អនិងពង្រីកកន្លែងប្រព្រឹត្តកម្មទឹកកខ្វក់ ដើម្បីការពារទឹកកខ្វក់ និងសំណល់ឧស្សាហកម្ម ចូលក្នុងទៅបំពុលប្រភពទឹកផ្សេង។ អនុវត្តបទប្បញ្ញត្តិស្តីពីការបោះចោលសំណល់ និង ប្រព្រឹត្តកម្មទឹកកខ្វក់ ឱ្យបានត្រឹមត្រូវនៅតាមទីក្រុងនិងជនបទ។
- **គ្រប់គ្រងទឹកកខ្វក់និងទឹកមានថ្នាំគីមីកសិកម្ម៖** អនុវត្តការប្រតិបត្តិកសិកម្មប្រកបដោយនិរន្តរភាព ដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមីគ្រោះថ្នាក់ថ្នាំសម្លាប់សត្វល្អិតនិងជី។ លើកកម្ពស់កសិកម្មសរីរាង្គ និងបច្ចេកទេសគ្រប់គ្រង

ទឹកឱ្យកាន់តែប្រសើរឡើង ដើម្បីការពារទឹកកខ្វក់ទៅបំពុលទឹកទន្លេ ព្រែក ស្ទឹង និងបឹង។

- **ពង្រឹងការអប់រំសាធារណៈនិងការចូលរួមសហគមន៍៖** លើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃទឹកស្អាត និងការបោះចោលសំណល់ឱ្យបានត្រឹមត្រូវ។ លើកទឹកចិត្តឱ្យមានការចូលរួមរបស់សហគមន៍ ក្នុងសកម្មភាពសម្អាត ការអនុវត្តអនាម័យត្រឹមត្រូវ និងការប្រើប្រាស់ទឹកប្រកបដោយការទទួលខុសត្រូវ ដើម្បីកាត់បន្ថយការបំពុលនៅតាមមូលដ្ឋាន។

**គ. ការគ្រប់គ្រងសំរាម**

- **កែលម្អប្រព័ន្ធប្រមូលនិងទុកដាក់សំរាម៖** ពង្រីក និងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រមូលសំរាម ដើម្បីធានាពីលទ្ធភាពទទួលបានសេវាគ្រប់គ្រងសំរាមជាប្រចាំ និងទូលំទូលាយ ជាពិសេសនៅតំបន់ទីក្រុង។ លើកកម្ពស់ការធ្វើជីកំប៉ុស និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីការចោលសំរាមប្រកបដោយការទទួលខុសត្រូវ។
- **ជំរុញការញែកនិងការកែច្នៃសំរាម៖** លើកទឹកចិត្តឱ្យមានការបែងចែកសំរាមតាមប្រភេទនៅក្នុងគ្រួសារ អាជីវកម្ម និងឧស្សាហកម្ម ហើយអនុវត្តកម្មវិធីកែច្នៃឡើងវិញ ដើម្បីកាត់បន្ថយបរិមាណសំណល់ដែលដឹកទៅទីលានចាក់សំរាម ឬកន្លែងដុតសំរាម ដើម្បីរក្សាសោភ័ណភាពប្រទេសឱ្យបានស្អាត។
- **កែច្នៃសំរាមឱ្យទៅជាថាមពលនិងធ្វើជីកំប៉ុស៖** វិនិយោគលើបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធនៃការកែច្នៃសំរាមឱ្យទៅជាថាមពល (Waste-to-energy) ដោយប្រើប្រាស់បច្ចេកវិទ្យាបៃតង ដូចជាការរំលាយចោលដោយបច្ចេកទេស Anaerobic ឬការដុតសំរាមក្នុងសីតុណ្ហភាពខ្ពស់។ ជំរុញឱ្យមានការធ្វើជីកំប៉ុសពីសំរាមសរីរាង្គ ដើម្បីកាត់បន្ថយបរិមាណសំរាមនៅកន្លែងទីលានចាក់សំរាម និងបង្កើតថាមពលជីវៈឧស្ម័ន (Bio Gas) ឬផលិតផលមានប្រយោជន៍ផ្សេងទៀត។

### ឃ. ការបំពុលខ្យល់ឆ្លងដែន

- **ការបំពុលខ្យល់ឆ្លងដែន៖** ក្នុងករណីបានទទួលការផ្តល់ដំណឹង ការផ្តល់របាយការណ៍ ឬលទ្ធផលសិក្សាពីការបំពុលខ្យល់ឆ្លងដែន ក្រសួងទទួលបន្ទុកវិស័យបរិស្ថាន និងធនធានធម្មជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីស្វែងរកមធ្យោបាយក្នុងការកាត់បន្ថយផលប៉ះពាល់ពីការបំពុលខ្យល់ឆ្លងដែនតាមរយៈយន្តការទ្វេភាគី ពហុភាគី និងតំបន់។
- **ការបំពុលខ្យល់ឆ្លងដែនពីប្រភពក្នុងស្រុក៖** ក្នុងករណីកើតមានការបំពុលខ្យល់ក្នុងស្រុក ដែលស្ថានភាពនៃការបំពុលអាចបង្កឱ្យមានការឆ្លងដែនអាចប៉ះពាល់ដល់ ប្រទេសជិតខាង និងតំបន់ ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិដោយសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវចាត់វិធានការកាត់-បន្ថយឱ្យអស់លទ្ធភាព និងត្រូវជូនដំណឹងទៅប្រទេស និងតំបន់ដែលទទួលរងប៉ះពាល់។

# ៦.សកម្មភាពការងារ

## ៦.១ ការកសាងសមត្ថភាពការទូតបរិស្ថាន(ឆ្នាំ២០២៦-២០២៧)

- ពង្រឹងសមត្ថភាពអ្នកការទូតនិងអ្នកពាក់ព័ន្ធ ដើម្បីអនុវត្តការទូតបរិស្ថាន
- ធ្វើការជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីបង្កើតក្របខ័ណ្ឌការងារការទូតបរិស្ថាន
- ធ្វើបច្ចុប្បន្នភាពបញ្ហាបំពុលឆ្លងដែន នៅក្នុងតំបន់និងអន្តរជាតិ
- ធ្វើកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធជាតិ វិស័យឯកជន និងអន្តរជាតិ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការគ្រប់គ្រងបរិស្ថាននិងពង្រឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា ឆ្នាំ២០២៦-២០៣០
- អនុវត្តការតាមដាននិងត្រួតពិនិត្យ និងធ្វើរបាយការណ៍រីកចម្រើននិងតម្រង់ទិសសម្រាប់ឆ្នាំខាងមុខ។

## ៦.២ ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ(២០២៧-២០២៨)

### ក. ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់សកម្មភាព

**សកម្មភាព ៦.២.១៖** ចរចាជាមួយដៃគូអភិវឌ្ឍ និងប្រទេសជាដៃគូ ដើម្បីទទួលបានជំនួយបច្ចេកទេស។

**សកម្មភាព ៦.២.២៖** ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងតំបន់ លើការគ្រប់គ្រងព្រៃឈើ និងការចូលរួមពីសហគមន៍ តាមរយៈការចែករំលែកបទពិសោធ និងការអនុវត្តល្អៗ។

**សកម្មភាព ៦.២.៣៖** រៀបចំយន្តការសហការជាមួយប្រទេសជាដៃគូ និងអង្គការអន្តរជាតិ ដើម្បីអនុវត្តគម្រោងដាំដើមឈើ និងស្តារព្រៃឈើឡើងវិញ ក្នុងគោលដៅបង្កើនសន្និធិកាបូន និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

**សកម្មភាព ៦.២.៤៖** ចូលរួមជាមួយគំនិតផ្តួចផ្តើមអន្តរជាតិ ដូចជាកិច្ចព្រមព្រៀងទីក្រុងប៉ារីស (Paris Agreement) និងយន្តការនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD+) ដើម្បីទទួលបានការគាំទ្រនិងហិរញ្ញប្បទាន។

**សកម្មភាព ៦.២.៥៖** ចរចាជាមួយដៃគូអភិវឌ្ឍ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដើម្បីទទួលបានហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍគម្រោងថាមពលកកើតឡើងវិញ។

**សកម្មភាព ៦.២.៦៖** ជំរុញកិច្ចសហប្រតិបត្តិការតំបន់លើការផ្លាស់ប្តូរពីការប្រើប្រាស់ ឥន្ធនៈហ្វូស៊ីល មកប្រើប្រាស់ថាមពលស្អាត តាមរយៈការចែករំលែកបច្ចេកវិទ្យា និងការវិនិយោគឆ្លងដែន។

**សកម្មភាព ៦.២.៧៖** រៀបចំកិច្ចប្រជុំ និងសិក្ខាសាលាអន្តរជាតិ ដើម្បីផ្សព្វផ្សាយ និងលើកកម្ពស់ការអនុវត្តបច្ចេកវិទ្យាបៃតងក្នុងវិស័យឧស្សាហកម្ម និងការគ្រប់គ្រងសំណល់។

**សកម្មភាព ៦.២.៨៖** ចូលរួមជាមួយកិច្ចព្រមព្រៀងបរិស្ថានពហុភាគី (MEAs) និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការគ្រប់គ្រង សារធាតុបំពុល។

**សកម្មភាព ៦.២.៩៖** បង្កើតយន្តការសហការជាមួយវិស័យឯកជនអន្តរជាតិ ដើម្បីទាក់ទាញការវិនិយោគបៃតង តាមរយៈការផ្តល់ការលើកទឹកចិត្តពន្ធ និងការសម្របសម្រួលបទប្បញ្ញត្តិ។

**សកម្មភាព ៦.២.១០៖** ចរចា និងចូលរួមក្នុងទីផ្សារកាបូនអន្តរជាតិ ដើម្បីទទួលបានឥណទានកាបូន និងហិរញ្ញប្បទានសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

**ខ. ការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ**

**សកម្មភាព ៦.២.១១៖** សហការជាមួយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីរៀបចំកម្មវិធីអប់រំ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីការបន្សុាំខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។

**សកម្មភាព ៦.២.១២៖** ចែករំលែកបទពិសោធនិងការអនុវត្តល្អៗ ជាមួយប្រទេសជាសមាជិកអាស៊ាន និងដៃគូសន្ទនា លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការកសាងភាពធន់របស់សហគមន៍។

**សកម្មភាព ៦.២.១៣៖** ចូលរួមក្នុងគណៈកម្មការទន្លេមេគង្គ (MRC) និងយន្តការសហប្រតិបត្តិការតំបន់ផ្សេងទៀត ដើម្បីពង្រឹងការគ្រប់គ្រងធនធានទឹកឆ្លងដែនប្រព័ន្ធគ្រប់គ្រងទឹកជំនន់ និងការស្តុកទឹក។

**សកម្មភាព ៦.២.១៤៖** ជំរុញការដាក់បញ្ចូលដំណោះស្រាយផ្អែកលើធម្មជាតិ (Nature-based Solutions) ទៅក្នុងគម្រោងសហប្រតិបត្តិការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាមួយដៃគូអន្តរជាតិ។

**សកម្មភាព ៦.២.១៥៖** ស្នើសុំជំនួយបច្ចេកទេស និងហិរញ្ញប្បទានពីមូលនិធិអាកាសធាតុបៃតង (GCF) និងមូលនិធិអន្តរជាតិផ្សេងទៀត សម្រាប់គម្រោងកសិកម្មធន់នឹងអាកាសធាតុ និងការធ្វើពិពិធកម្មដំណាំ។

**សកម្មភាព ៦.២.១៦៖** ធ្វើការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំវេទិកាតំបន់និងអន្តរជាតិ ដើម្បីផ្សព្វផ្សាយពូជដំណាំដែលធន់នឹងគ្រោះរាំងស្ងួតនិងទឹកជំនន់ និងទាក់ទាញការវិនិយោគពីបណ្តាប្រទេសដៃគូ។

**គ. អភិបាលកិច្ចល្អ**

**សកម្មភាព ៦.២.១៧៖** ពង្រឹងការសម្របសម្រួលគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុជាមួយកិច្ចព្រមព្រៀងអន្តរជាតិ ដូចជាកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)។

**សកម្មភាព ៦.២.១៨៖** ចូលរួមយ៉ាងសកម្មក្នុងការចរចាអន្តរជាតិ និងតំបន់ ស្តីពីការប្រែ-ប្រួលអាកាសធាតុ និងបរិស្ថាន ដើម្បីបង្ហាញពីគោលជំហរជាតិ និងពង្រឹងកិច្ចសហ-ប្រតិបត្តិការ។
**សកម្មភាព ៦.២.១៩៖** បង្កើតយន្តការពិគ្រោះយោបល់ និងភាពជាដៃគូ ជាមួយអង្គការសង្គមស៊ីវិលអន្តរជាតិនិងវិស័យឯកជន ក្នុងការអភិវឌ្ឍ និងអនុវត្តគោលនយោបាយអាកាសធាតុ។
**សកម្មភាព ៦.២.២០៖** រៀបចំរបាយការណ៍វឌ្ឍនភាពជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ និងបរិស្ថាន ប្រកបដោយតម្លាភាព និងគណនេយ្យភាព ដើម្បីបង្ហាញ ជូនសហគមន៍អន្តរជាតិ។
**សកម្មភាព ៦.២.២១៖** ពង្រឹងភាពជាដៃគូសាធារណៈនិងឯកជន(PPPs) ជាមួយដៃគូអន្តរ-ជាតិ ដើម្បីទាក់ទាញការវិនិយោគ និងការផ្ទេរបច្ចេកវិទ្យាសម្រាប់វិស័យបៃតង។
**សកម្មភាព៦.២.២២៖** កសាងសមត្ថភាពស្ថាប័នជាតិតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីទទួលបានហិរញ្ញប្បទានអាកាសធាតុដោយផ្ទាល់ពីមូលនិធិអន្តរជាតិ ជាពិសេស មូលនិធិអាកាសធាតុបៃតង (GCF)។
**សកម្មភាព ៦.២.២៣៖** ធ្វើការភ្ជាប់ទំនាក់ទំនងជាមួយបណ្តាញការទូតបរិស្ថានក្នុងតំបន់ និងអន្តរជាតិ ក្នុងគោលបំណងផ្លាស់ប្តូរព័ត៌មាន និងបទពិសោធក៏ដូចជាពង្រឹងជំហររបស់កម្ពុជាលើឆាកអន្តរជាតិ។

## ៦.៣ ការថែរក្សាប្រព័ន្ធអេកូឡូស៊ី(២០២៨-២០២៩)

### ក. ការអភិរក្សជីវៈចម្រុះ

**សកម្មភាព ៦.៣.១៖** ចរចាជាមួយដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ ដើម្បីទទួលបានជំនួយបច្ចេកទេស និងហិរញ្ញប្បទានសម្រាប់ការពង្រឹងការអនុវត្តច្បាប់១០០% នៅក្នុងតំបន់ការពារធម្មជាតិ ស្របតាមក្រមបរិស្ថាននិងធនធានធម្មជាតិ។
**សកម្មភាព ៦.៣.២៖** រៀបចំកិច្ចប្រជុំទ្វេភាគី និងពហុភាគី ជាមួយក្រសួងយុត្តិធម៌ ស្ថាប័នពាក់ព័ន្ធ និងដៃគូអន្តរជាតិ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើការទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ និងអំពើពុករលួយ។

**សកម្មភាព ៦.៣.៣៖** ស្នើសុំការគាំទ្រពីអង្គការអន្តរជាតិ និងប្រទេសជាដៃគូ សម្រាប់ការផ្តល់ផែនទីតំបន់ការពារ រូបភាពផ្កាយរណប យន្តហោះគ្មានមនុស្សបើក (Drone) និងឧបករណ៍ល្បាតទំនើប ដើម្បីបង្កើនប្រសិទ្ធភាពការងារអភិរក្ស។

**សកម្មភាព ៦.៣.៤៖** ភ្ជាប់ទំនាក់ទំនងជាមួយអនុសញ្ញាអន្តរជាតិស្តីពីជីវៈចម្រុះ (CBD) និងយន្តការពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរបទពិសោធ និងទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។

## ខ. ការស្តារព្រៃឈើឡើងវិញ

**សកម្មភាព ៦.៣.៥៖** សហការជាមួយអង្គការអន្តរជាតិ និងប្រទេសជាដៃគូ ដើម្បីបង្កើតថ្នាលបណ្តុះកូនឈើថ្នាក់តំបន់ចំនួន៥ និងថ្នាលបណ្តុះកូនឈើថ្នាក់ខេត្ត នៅទូទាំងប្រទេសដោយទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងពូជកូនឈើដែលមានគុណភាព។

**សកម្មភាព៦.៣.៦៖** រៀបចំយុទ្ធនាការចែកកូនឈើដោយមិនគិតថ្លៃក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីលើកកម្ពស់ការចូលរួមរបស់សាធារណជន និងសហគមន៍ក្នុងការដាំដើមឈើនៅតាមគេហដ្ឋាន និងតំបន់ព្រៃរេចរឹល។

**សកម្មភាព ៦.៣.៧៖** ស្នើសុំជំនួយបច្ចេកទេសពីអ្នកជំនាញអន្តរជាតិ លើការជ្រើសរើសប្រភេទដើមឈើដែលសមស្របនឹងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ ដើម្បីធានាអត្រារស់រានមានជីវិតខ្ពស់ និងបង្កើនសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដូចជាការថែរក្សាទឹក និងការស្រូបយកកាបូន។

**សកម្មភាព ៦.៣.៨៖** ចូលរួមក្នុងគំនិតផ្តួចផ្តើមស្តារព្រៃឈើក្នុងតំបន់ និងអន្តរជាតិ ដូចជាកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ និងគោលដៅទីក្រុងបោន ឆ្នាំ២០៣០ (Bonn Challenge) ដើម្បីទទួលបានការគាំទ្រ និងទទួលស្គាល់ពីសហគមន៍អន្តរជាតិ។

## គ. ជីវភាពសហគមន៍

**សកម្មភាព ៦.៣.៩៖** សហការជាមួយអង្គការទេសចរណ៍អន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីអភិវឌ្ឍគម្រោងទេសចរណ៍ធម្មជាតិប្រកបដោយចីរភាព នៅក្នុងតំបន់ការពារដោយផ្តល់ការបណ្តុះបណ្តាលដល់សហគមន៍មូលដ្ឋានលើជំនាញមគ្គុទ្ទេសក៍ទេសចរ ការគ្រប់គ្រងកន្លែងស្នាក់នៅ និងការផលិតនូវផលិតផលសិប្បកម្ម។

**សកម្មភាព ៦.៣.១០៖** រៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយ និងតាំងពិពណ៌អន្តរជាតិ ដើម្បីផ្សព្វផ្សាយផលិតផលទេសចរណ៍ធម្មជាតិ និងផលិតផលសហគមន៍កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ។

**សកម្មភាព៦.៣.១១៖** ស្នើសុំជំនួយបច្ចេកទេសនិងហិរញ្ញប្បទានពីអង្គការអន្តរជាតិ សម្រាប់ការបណ្ដុះបណ្ដាលសហគមន៍មូលដ្ឋាន លើការធ្វើកសិកម្មប្រកបដោយនិរន្តរភាព ការនេសាទ ការចិញ្ចឹមសត្វ និងការប្រមូលផលអនុផលព្រៃឈើ (ដូចជា ទឹកឃ្មុំ ផ្សិត ឫស្សី រុក្ខជាតិឱសថ) ដោយអនុលោមតាមគោលដៅអភិរក្ស។

**សកម្មភាព ៦.៣.១២៖** បង្កើតយន្តការសហការជាមួយអង្គការសង្គមស៊ីវិលអន្តរជាតិ និងដៃគូអភិវឌ្ឍ ដើម្បីពង្រឹងការចូលរួមរបស់សហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រង តំបន់ការពារធម្មជាតិ និងធានាថាផលប្រយោជន៍ពីការអភិរក្សត្រូវបានចែករំលែក ដោយសមធម៌។

**សកម្មភាព ៦.៣.១៣៖** ចូលរួមក្នុងវេទិកាអន្តរជាតិ និងតំបន់ ស្ដីពីការចូលរួមរបស់សហគមន៍ក្នុងការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីផ្លាស់-ប្ដូរបទពិសោធនិងពង្រឹងបណ្ដាញភាពជាដៃគូ។

## ៦.៤. កិច្ចគាំពារបរិស្ថាន(ឆ្នាំ២០២៩-២០៣០)

### ក. ការបំពុលខ្យល់

**សកម្មភាព ៦.៤.១៖** ចរចាជាមួយដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ ដើម្បីទទួលបានជំនួយបច្ចេកទេសនិងហិរញ្ញប្បទាន សម្រាប់ពង្រឹងបទប្បញ្ញត្តិគុណភាពខ្យល់ និងប្រព័ន្ធត្រួតពិនិត្យការបំពុលឱ្យស្របតាមស្ដង់ដាអន្តរជាតិ។

**សកម្មភាព ៦.៤.២៖** សហការជាមួយអង្គការសុខភាពពិភពលោក (WHO) និងទីភ្នាក់ងារបរិស្ថានអន្តរជាតិ ដើម្បីរៀបចំយុទ្ធនាការផ្សព្វផ្សាយអំពីផលប៉ះពាល់សុខភាពនៃការបំពុលបរិយាកាស និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ។

**សកម្មភាព ៦.៤.៣៖** ចូលរួមក្នុងវេទិកាតំបន់និងអន្តរជាតិ ស្ដីពីការគ្រប់គ្រងគុណភាពខ្យល់ និងការកាត់បន្ថយការបំពុលបរិយាកាសដើម្បីផ្លាស់ប្ដូរបទពិសោធ និងការអនុវត្តល្អៗ។

**សកម្មភាព ៦.៤.៤៖** ស្នើសុំការគាំទ្រពីដៃគូអន្តរជាតិ សម្រាប់ការផ្លាស់ប្តូរឆ្ពោះទៅរកប្រភពថាមពលកកើតឡើងវិញ (ពន្លឺព្រះអាទិត្យ ខ្យល់) និងការលើកកម្ពស់ ការប្រើប្រាស់យានជំនិះអគ្គិសនី តាមរយៈការផ្ទេរបច្ចេកវិទ្យា និងហិរញ្ញប្បទានអនុគ្រោះ។

**សកម្មភាព ៦.៤.៥៖** ចរចាជាមួយដៃគូអភិវឌ្ឍ ដើម្បីទទួលបានជំនួយសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនសាធារណៈ និងការប្រើប្រាស់ឥន្ធនៈស្អាតក្នុងគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នពីវិស័យដឹកជញ្ជូន។

**ខ. ការបំពុលទឹក**

**សកម្មភាព ៦.៤.៦៖** ស្នើសុំជំនួយបច្ចេកទេស និងហិរញ្ញប្បទានពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (World Bank) និងដៃគូអភិវឌ្ឍផ្សេងទៀត សម្រាប់ការកែលម្អ និងពង្រីកកន្លែងប្រព្រឹត្តកម្មទឹកកខ្វក់ នៅតាមទីក្រុង និងជនបទ។

**សកម្មភាព ៦.៤.៧៖** សហការជាមួយគណៈកម្មការទន្លេមេគង្គ (MRC) និងប្រទេសជាសមាជិកដើម្បីពង្រឹងការគ្រប់គ្រងគុណភាពទឹក និងការពារការបំពុលនៅក្នុងអាងទន្លេមេគង្គ និងបឹងទន្លេសាប។

**សកម្មភាព ៦.៤.៨៖** ចូលរួមក្នុងកិច្ចព្រមព្រៀងបរិស្ថានពហុភាគី (MEAs) និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងសារធាតុគីមីគ្រោះថ្នាក់ និងការការពារប្រភពទឹក។

**សកម្មភាព ៦.៤.៩៖** ស្នើសុំជំនួយបច្ចេកទេសពីអង្គការស្បៀង និងកសិកម្ម (FAO) និងដៃគូអន្តរជាតិផ្សេងទៀត សម្រាប់ការលើកកម្ពស់កសិកម្មសរីរាង្គ និងបច្ចេកទេសគ្រប់គ្រងទឹកប្រកបដោយនិរន្តរភាព។

**សកម្មភាព ៦.៤.១០៖** រៀបចំកម្មវិធីអប់រំ និងផ្សព្វផ្សាយជាសាធារណៈ ដោយមានការគាំទ្រពីអង្គការអន្តរជាតិ អំពីសារៈសំខាន់នៃទឹកស្អាត និងការបោះចោលសំណល់ឱ្យបានត្រឹមត្រូវ និងលើកទឹកចិត្តដល់ការចូលរួមពីសហគមន៍។

**គ. ការគ្រប់គ្រងសំរាម**

**សកម្មភាព ៦.៤.១១៖** ចរចាជាមួយដៃគូអភិវឌ្ឍ និងអង្គការអន្តរជាតិ ដើម្បីទទួលបានជំនួយហិរញ្ញប្បទាននិងបច្ចេកទេស សម្រាប់ការពង្រីកនិងធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធប្រមូល និងទុកដាក់សំរាម ជាពិសេសនៅតំបន់ទីក្រុង។

**សកម្មភាព ៦.៤.១២៖** សហការជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល (NGOs) ដើម្បីរៀបចំយុទ្ធនាការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ អំពីការចោលសំរាមប្រកបដោយការទទួលខុសត្រូវ និងការធ្វើជីកំប៉ុស។

**សកម្មភាព ៦.៤.១៣៖** សិក្សាបទពិសោធពីប្រទេសជឿនលឿននិងដៃគូអន្តរជាតិ លើការអនុវត្តកម្មវិធីញែកសំរាមតាមប្រភេទ និងការកែច្នៃសំរាមឡើងវិញ ដើម្បីអនុវត្តនៅកម្ពុជា។

**សកម្មភាព ៦.៤.១៤៖** ស្នើសុំការវិនិយោគ និងការផ្ទេរបច្ចេកវិទ្យាពីបណ្ដាប្រទេស ជាដៃគូសម្រាប់ការអភិវឌ្ឍគម្រោងកែច្នៃសំរាមឱ្យទៅជាថាមពល (Waste-to-Energy) ដោយប្រើប្រាស់បច្ចេកវិទ្យាបៃតងដូចជា ការរំលាយដោយបច្ចេកទេស Anaerobic ឬការដុតកម្ដៅខ្ពស់។

**សកម្មភាព៦.៤.១៥៖** ចូលរួមក្នុងគំនិតផ្ដួចផ្ដើមតំបន់និងអន្តរជាតិ ស្ដីពីការគ្រប់គ្រងសំណល់ប្លាស្ទិកនិងសំណល់គ្រោះថ្នាក់ ដើម្បីទទួលបានការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុ។

**សកម្មភាព ៦.៤.១៦៖** លើកកម្ពស់កិច្ចសហប្រតិបត្តិការសាធារណៈនិងឯកជន (PPP) ជាមួយវិស័យឯកជនអន្តរជាតិ ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធកែច្នៃ សំរាមឱ្យទៅជាថាមពល និងផលិតជីកំប៉ុសពីសំរាមសរីរាង្គ។

# ៧. ធនធានហិរញ្ញវត្ថុ

## ៧.១ ប្រភពថវិកា

ដើម្បីធានាការអនុវត្តយុទ្ធសាស្ត្រការទូតបរិស្ថានឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រនេះត្រូវការថវិកាចំនួន ២៣ ០០០លានរៀល ក្នុងនោះយុទ្ធសាស្ត្រនេះនឹងកៀរគរថវិកាពីបណ្ដាដៃគូរបស់ប្រទេសកម្ពុជាដែលមានស្រាប់ ជាពិសេសគឺមូលនិធិអាកាសធាតុបៃតង មូលនិធិកិច្ចបាត់បង់និងខូចខាត មូលនិធិបរិស្ថានសកល មូលនិធិបន្សាំជាដើម។

## ៧.២ យន្តការ

ដោយហេតុថា បរិស្ថាន គឺជាសសរស្ដម្ភមួយ ក្នុងចំណោមសសរស្ដម្ភពីរទៀត

គឺសេដ្ឋកិច្ច និងសង្គម ដែលត្រូវតែថ្លឹងថ្លែងឱ្យមានតុល្យភាពនឹងគ្នា សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា ហេតុដូច្នេះហើយយន្តការដែលមានស្រាប់ត្រូវតែពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីសម្របសម្រួលការអនុវត្តការងារឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។ ការសម្របសម្រួលក្នុងចំណោមភាគីពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ គឺជាកត្តាចាំបាច់ ក្នុងការបំពេញតួនាទីនិងភារកិច្ចនៃយន្តការនីមួយៗ សំដៅឱ្យសម្រេចបាននូវសមិទ្ធផលជាតិក្នុងវិស័យបរិស្ថាន។ យន្តការទាំងអស់នោះ រួមមានយន្តការអន្តរក្រសួង យន្តការក្រុមការងារ និងយន្តការថ្នាក់ក្រោមជាតិ។

## ៧.២.១ យន្តការអន្តរក្រសួង

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥១៥/៤០៣ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៥។ ក.ជ.អ.ច. ជាស្ថាប័នរៀបចំគោលនយោបាយ ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងធានាបាននូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន និងសង្គម ក្នុងព្រះរាជាណាចក្រកម្ពុជា។ សមាសភាព ក.ជ.អ.ច. រួមមាន នាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន និងមានរដ្ឋលេខាធិការ ព្រមទាំងអគ្គលេខាធិការមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្ត សរុបចំនួន៣៧ ជាអនុប្រធាន និងសមាជិក។

ក្រសួងទទួលបន្ទុកវិស័យបរិស្ថាននិងធនធានធម្មជាតិត្រូវសហការជាមួយនឹងក្រសួង ស្ថាប័នមានសមត្ថកិច្ចជាពិសេស ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តផែនការឆ្លើយតបបន្ទាន់ទាក់ទងទៅនឹងការបំពុលសមុទ្រពីដីគោក ការដឹកជញ្ជូនតាមជលយាន ការធ្វើអាជីវកម្ម ឬរ៉ែបាតសមុទ្រ និងការដោះស្រាយបញ្ហាបំពុលបរិស្ថានសមុទ្រឆ្លងដែន។

ក្នុងនាមជាយន្តការអន្តរក្រសួង បេសកកម្មរបស់ ក.ជ.អ.ច. រួមមាន ការបង្កើត និងវាយតម្លៃគោលនយោបាយ យុទ្ធសាស្ត្រ ការប្រមូលធនធាន ការកសាងសមត្ថភាព និងការពង្រឹងកិច្ចសហប្រតិបត្តិការទាក់ទងនឹងការអភិវឌ្ឍប្រកបដោយចីរភាព ជាពិសេស ការគ្រប់គ្រងធនធានធម្មជាតិ។ ក.ជ.អ.ច មានតួនាទី និងការទទួលខុសត្រូវ ដូចខាងក្រោម៖

- គោលនយោបាយនិងការគ្រប់គ្រងកម្មវិធី៖ បង្កើត អនុវត្ត សម្របសម្រួល និង វាយតម្លៃគោលនយោបាយ ឯកសារច្បាប់ ផែនការយុទ្ធសាស្ត្រ និងគម្រោង នានាពាក់ព័ន្ធនឹងការអភិវឌ្ឍប្រកបដោយចីរភាព
- ភាពជាអ្នកដឹកនាំនៅក្នុងវិស័យនិរន្តរភាព៖ ដឹកនាំ គ្រប់គ្រង និងសម្របសម្រួល កិច្ចការ សេដ្ឋកិច្ចបៃតង ការប្រែប្រួលអាកាសធាតុ ការអភិរក្សជីវៈចម្រុះ និង ការលើកកម្ពស់ជីវភាពរស់នៅប្រកបដោយចីរភាព
- ការភ្ជាប់ទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ និងភាពជាដៃគូ៖ កសាង និងពង្រីកកិច្ច-សហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន និងស្ថាប័នអប់រំ
- ការអភិវឌ្ឍចំណេះដឹងនិងសមត្ថភាព៖ លើកកម្ពស់ការស្រាវជ្រាវ ការអប់រំ ការ បណ្តុះបណ្តាល ការផ្ទេរបច្ចេកវិទ្យា និងការផ្សព្វផ្សាយ ដើម្បីបង្កើនការអនុវត្តការ អភិវឌ្ឍប្រកបដោយចីរភាព
- ការកៀរគរធនធាន៖ ធានាការគាំទ្រ និងធនធាន សម្រាប់ការអនុវត្តគំនិតផ្តួចផ្តើម នៃការអភិវឌ្ឍប្រកបដោយចីរភាព

អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (អ.ក.អ.ច) មានតួនាទី សំខាន់ក្នុងការគាំទ្រដល់ដំណើរការនិងមុខងារនៃ ក.ជ.អ.ច ដូចខាងក្រោម៖

- ការគាំទ្រគោលនយោបាយនិងផែនការ៖ ជួយក្នុងការអភិវឌ្ឍនិងរៀបចំឯកសារ ច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងគម្រោងនានាដែលពាក់ព័ន្ធនឹងការ អភិវឌ្ឍប្រកបដោយចីរភាព
- ការគ្រប់គ្រងប្រតិបត្តិការ៖ គ្រប់គ្រងប្រតិបត្តិការប្រចាំថ្ងៃរបស់ ក.ជ.អ.ច. ដើម្បី ធានាបាននូវដំណើរការមុខងារប្រកបដោយភាពរលូន និងកិច្ចការរដ្ឋបាល ប្រកបដោយប្រសិទ្ធភាព
- ការប្រតិបត្តិនិងការត្រួតពិនិត្យ៖ សម្របសម្រួល និងគាំទ្រការអនុវត្តគំនិតផ្តួចផ្តើម ការអភិវឌ្ឍប្រកបដោយចីរភាព រួមទាំងការត្រួតពិនិត្យនិងការវាយតម្លៃវឌ្ឍនភាព ការងារ

- ចំណេះដឹងនិងការប្រាស្រ័យទាក់ទង៖ សម្របសម្រួលការស្រាវជ្រាវ ការអប់រំ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយព័ត៌មាន និងចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិ និងព្រឹត្តិការណ៍ពាក់ព័ន្ធផ្សេងទៀត ដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព
- ការគ្រប់គ្រងធនធាននិងភាពជាដៃគូ៖ កៀរគរនិងគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ រួមមានដៃគូអភិវឌ្ឍ សង្គមស៊ីវិល និងវិស័យឯកជន។

### ៧.២.២ យន្តការក្រុមការងារ

**ក. ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ** (TWG-CC )**៖** មានភារកិច្ច ពង្រឹងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសជាតិ ដូចខាងក្រោម៖

- សមាហរណកម្មគោលនយោបាយនិងផែនការ៖ រួមចំណែកក្នុងការអភិវឌ្ឍ និងអនុវត្តគោលនយោបាយប្រែប្រួលអាកាសធាតុ និងបញ្ជ្រាបបញ្ហាអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍនានា
- ការណែនាំបច្ចេកទេសរបស់អ្នកជំនាញ៖ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសឯកទេសដល់ ក.ជ.អ.ច. លើបញ្ហានៃការប្រែប្រួលអាកាសធាតុ
- ការសម្របសម្រួលជាមួយវិស័យពាក់ព័ន្ធ៖ សម្របសម្រួលកិច្ចសហការរវាងស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការក្រៅរដ្ឋាភិបាល និងវិស័យឯកជន ដើម្បី ធានាបាននូវសកម្មភាពអាកាសធាតុរួមគ្នា
- ការត្រួតពិនិត្យនិងការរាយការណ៍៖ តាមដានវឌ្ឍនភាព វាយតម្លៃយុទ្ធសាស្ត្រ និងរួមចំណែកដល់ការរាយការណ៍ជាតិក្រោម UNFCCC
- ការកសាងសមត្ថភាពនិងការកៀរគរធនធាន៖ បង្កើនសមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការចែករំលែកចំណេះដឹង ការផ្ទេរបច្ចេកវិទ្យា និងការចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងហិរញ្ញវត្ថុអាកាសធាតុ។

**ខ. ក្រុមការងារបច្ចេកទេសជីវៈចម្រុះ** (TWG-BD)**៖** ប្រទេសកម្ពុជាដើរតួនាទី យ៉ាងសំខាន់ក្នុងការសម្របសម្រួល និងអនុវត្តកិច្ចខិតខំប្រឹងប្រែង ដើម្បីការពារធនធានធម្មជាតិដ៏សម្បូរបែបរបស់ប្រទេស និងមានភារកិច្ច ដូចខាងក្រោម៖

- ការគាំទ្រការរៀបចំនិងការអនុវត្តគោលនយោបាយ៖ ផ្តល់ប្រឹក្សាដល់អ្នកធ្វើគោល-នយោបាយពាក់ព័ន្ធនឹងជីវៈចម្រុះ រួមចំណែកក្នុងការអភិវឌ្ឍ និងការពិនិត្យឡើងវិញនូវច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងជួយក្នុងការអនុវត្តកិច្ចព្រមព្រៀងជីវៈចម្រុះអន្តរជាតិ
- ការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ៖ ដើរតួនាទីជាវេទិកាចម្បង សម្រាប់ជំរុញកិច្ចសហការក្នុងចំណោមភាគីពាក់ព័ន្ធនានា ដើម្បីធានាបាននូវការបែង-ចែកធនធានប្រកបដោយប្រសិទ្ធភាព និងសុដុមភាពនៃគោលនយោបាយនិងសកម្មភាពអភិរក្ស
- ការគាំទ្រជំនាញនិងការណែនាំបច្ចេកទេស៖ ក្រុមការងារនេះគាំទ្រផ្តល់ជំបូន្មានបច្ចេកទេស សម្របសម្រួលការចែករំលែកចំណេះដឹងនៃព័ត៌មានវិទ្យាសាស្ត្រ និងការអនុវត្តល្អៗ និងជំនួយគាំទ្រក្នុងការអភិវឌ្ឍ និងការអនុវត្តយុទ្ធសាស្ត្រអភិរក្ស និងផែនការសកម្មភាព
- ត្រួតពិនិត្យការអនុវត្តគម្រោងនិងការត្រួតពិនិត្យ៖ គាំទ្រការអនុវត្តគម្រោងអភិរក្សជីវៈចម្រុះ និងតាមដានប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងអភិរក្ស កំណត់តំបន់សម្រាប់ការកែលម្អ

• ការដោះស្រាយការងារអភិរក្ស៖ ផ្តោតលើតំបន់អភិរក្សជាក់លាក់ រួមមានការគ្រប់គ្រងតំបន់ការពារ ការអភិរក្សប្រភេទសត្វ ការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី ការចូលរួមរបស់សហគមន៍ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវៈចម្រុះ និងការស្រាវជ្រាវនិងការត្រួតពិនិត្យជីវៈចម្រុះ។

## គ. ក្រុមការងារអាស៊ាន

ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការបរិស្ថានអាស៊ាន កម្ពុជាបានបង្កើតក្រុមការងារផ្សេងៗ ដើម្បីការបន្សុីរវាងគោលនយោបាយបរិស្ថានជាតិ និងគោលនយោបាយតំបន់ ដូចខាងក្រោម៖

- **ក្រុមការងារប្រែប្រួលអាកាសធាតុអាស៊ាន** (AWGCC)៖ ដោយមើលឃើញពីភាពងាយរងគ្រោះរបស់កម្ពុជាចំពោះការប្រែប្រួលអាកាសធាតុ ក្រុមការងារ

នេះមានសារៈសំខាន់ក្នុងការដោះស្រាយយុទ្ធសាស្ត្រកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

- **ក្រុមការងារអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះអាស៊ាន** (AWGNCB)៖ មានសារៈសំខាន់សម្រាប់ប្រទេសកម្ពុជា ជាមួយនឹងជីវៈចម្រុះដ៏សម្បូរបែប ក្រុមការងារនេះ ផ្តោតលើការការពារ និងអភិរក្សធនធានធម្មជាតិ
- **ក្រុមការងារគ្រប់គ្រងធនធានទឹកអាស៊ាន** (AWGWRM)៖ ក្រុមការងារនេះមានសារៈសំខាន់សម្រាប់កម្ពុជា ដោយសារតែភាពពឹងផ្អែកស្ទើរតែទាំងស្រុងលើប្រព័ន្ធទន្លេមេគង្គដោយផ្តោតលើការលើកកម្ពស់ការគ្រប់គ្រងទឹកប្រកបដោយនិរន្តភាព
- **ក្រុមការងារទីក្រុងចីរភាពបរិស្ថានអាស៊ាន** (AWGESC)៖ នៅពេលដែលមជ្ឈ-មណ្ឌលទីក្រុងរបស់កម្ពុជារីកចម្រើន ការងាររបស់ក្រុមនេះគឺការលើកកម្ពស់ការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាពកាន់តែមានសារៈសំខាន់
- **ក្រុមការងារបរិស្ថានតំបន់ឆ្នេរនិងសមុទ្រអាស៊ាន** (AWGCME)៖ ខណៈពេលដែលខ្សែបន្ទាត់ឆ្នេរសមុទ្ររបស់កម្ពុជាមិនទូលំទូលាយដូចប្រទេសអាស៊ានមួយចំនួនទៀត តែតំបន់ឆ្នេរ និងសមុទ្រនៅតែមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កម្ពុជាដែលធ្វើឱ្យក្រុមការងារនេះមានសារសំខាន់ ក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការការពារសមុទ្រ
- **ក្រុមការងារសារធាតុគីមីនិងកាកសំណល់អាស៊ាន** (AWGCW)៖ មានសារៈ-សំខាន់ក្នុងការជួយគ្រប់គ្រង និងកាត់បន្ថយការបំពុល ដែលជាការព្រួយបារម្ភកាន់តែខ្លាំងឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍ
- **ក្រុមការងារអប់រំបរិស្ថានអាស៊ាន** (AWGEE)៖ ជួយកសាងសមត្ថភាពរបស់សហគមន៍អាស៊ានទាក់ទងនឹងកង្វល់បរិស្ថាន។

### ឃ. យន្តការថ្នាក់ក្រសួង

យោងតាមអនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ក្រសួងមានភារកិច្ចដឹកនាំនិងគ្រប់គ្រង

ការការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិសមស្របនិងនិរន្តរភាព និងលើកកម្ពស់ការរស់នៅប្រកបដោយចីរភាព ដើម្បីជាផលប្រយោជន៍យូរ-អង្វែងរបស់មនុស្សគ្រប់រូប និងគ្រប់ជំនាន់។ ក្រសួងបរិស្ថានមាន អគ្គលេខាធិការដ្ឋានចំនួន១(មួយ) និងអគ្គនាយកដ្ឋានចំនួន៦(ប្រាំមួយ) គឺ គោលនយោបាយនិងយុទ្ធ-សាស្ត្រ គាំពារបរិស្ថាន តំបន់ការពារធម្មជាតិ សហគមន៍មូលដ្ឋាន ចំណេះដឹងនិងព័ត៌មានបរិស្ថាន និងសវនកម្មផ្ទៃក្នុង។ ក្រសួងបរិស្ថានមានតួនាទីនិងភារកិច្ចការទទួលខុសត្រូវពាក់ព័ន្ធនឹងយន្តការអន្តរក្រសួង រួមមាន៖

- ការអភិវឌ្ឍគោលនយោបាយយុទ្ធសាស្ត្រ៖ រៀបចំគោលនយោបាយ ផែនការ និងអាទិភាពនានាក្នុងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ
- ការអនុវត្តក្របខ័ណ្ឌច្បាប់៖ រៀបចំ និងពង្រឹងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងការការពារបរិស្ថាន ជីវៈចម្រុះ ការគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅរបស់សហគមន៍
- ការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ៖ ធ្វើការជិតស្និទ្ធជាមួយក្រសួង ស្ថាប័ន ផ្សេងៗ ដើម្បីអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្របរិស្ថាន
- ការគ្រប់គ្រងបរិស្ថានគ្រប់ជ្រុងជ្រោយ៖ ត្រួតពិនិត្យ និងសម្របសម្រួលសកម្មភាពទាំងអស់ដែលទាក់ទងនឹងការការពារបរិស្ថាន ជីវៈចម្រុះ ធនធានធម្មជាតិ និងជីវភាពរស់នៅប្រកបដោយចីរភាព
- ការចូលរួមរបស់ភាគីពាក់ព័ន្ធ៖ គ្រប់គ្រងយ៉ាងសកម្ម និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ និងវិស័យឯកជន។

### ៧.២.៣ យន្តការថ្នាក់ក្រោមជាតិ

ស្របតាមតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រដ្ឋបាលរាជធានី ខេត្ត ត្រូវគាំទ្រការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព កម្មវិធី និងគម្រោងនានាទាក់ទងនឹងធនធានធម្មជាតិក្នុងដែនដីខ្លួន។ មន្ទីរ-បរិស្ថានរាជធានី ខេត្តគ្រប់គ្រងនិងត្រួតពិនិត្យបច្ចេកទេស ដោយមានការសម្របសម្រួលជាមួយរដ្ឋបាល និងបុគ្គលិករបស់ក្រសួងបរិស្ថាន។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវសហការជាមួយមន្ទីរបរិស្ថានរាជធានី ខេត្ត ដើម្បីអនុវត្តច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព សេចក្តីណែនាំ កម្មវិធី និងគម្រោងពាក់ព័ន្ធនានា។ ផ្អែកលើអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន នាយកដ្ឋានគឺមានភារកិច្ចនិងការទទួលខុសត្រូវទាំងនេះទាក់ទងនឹងយន្តការថ្នាក់ក្រោមជាតិ៖

- គោលនយោបាយនិងការអនុវត្តច្បាប់៖ ដឹកនាំការអនុវតច្បាប់ គោលនយោបាយបរិស្ថាន ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព
- ការការពារធនធានធម្មជាតិនិងជីវៈចម្រុះ៖ គ្រប់គ្រង និងទប់ស្កាត់ឧក្រិដ្ឋកម្មប្រឆាំងនឹងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងជំរុញការអភិវឌ្ឍសហគមន៍មូលដ្ឋាន
- ការពង្រឹងភាពអង់អាចសហគមន៍៖ គាំទ្រសហគមន៍មូលដ្ឋាន តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ការអប់រំបរិស្ថាន និងការល្បាតព្រៃឈើរួមគ្នា ដើម្បីបង្កើតការងារបៃតង និងប្រាក់ចំណូល
- កិច្ចសហការរបស់ភាគីពាក់ព័ន្ធ៖ ពង្រឹង និងពង្រីកភាពជាដៃគូជាមួយនឹងអាជ្ញាធរ មូលដ្ឋាន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងសហគមន៍មូលដ្ឋាន
- បុរេសកម្មភាពវិស័យបរិស្ថាន៖ ដើរតួនាទីជាអ្នកដឹកនាំក្នុងការគ្រប់គ្រង និងការពារបរិស្ថាន តាមរយៈកិច្ចខិតខំប្រឹងប្រែងចម្រុះនិងកិច្ចសហការ។

# ៨. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

## ៨.១ គោលបំណងនៃក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ

ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងនិរន្តរភាពនៃការអនុវត្តយុទ្ធសាស្ត្រការ-ទូតបរិស្ថាន តាមរយៈការតាមដានវឌ្ឍនភាពប្រចាំឆ្នាំ និងការវាយតម្លៃលទ្ធផលជាប្រព័ន្ធ។

## ៨.២ យន្តការតាមដានត្រួតពិនិត្យ

- របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ៖ ក្រុមការងារក្រសួងបរិស្ថានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព

- កិច្ចប្រជុំសម្របសម្រួលអន្តរក្រសួង៖ រៀបចំកិច្ចប្រជុំប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីពិនិត្យវឌ្ឍនភាព និងដោះស្រាយបញ្ហាប្រឈម
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យ៖ ធ្វើការប្រមូល និងវិភាគទិន្នន័យពាក់ព័ន្ធនឹងសូចនាករការអនុវត្ត
- ការត្រួតពិនិត្យថ្នាក់ក្រោមជាតិ៖ មន្ទីរបរិស្ថានរាជធានី ខេត្ត រាយការណ៍វឌ្ឍនភាពជូនថ្នាក់ជាតិ។

### ៨.៣ យន្តការវាយតម្លៃ

- ការវាយតម្លៃប្រចាំឆ្នាំ៖ វាស់វែងពីដំណើរការនៃការអនុវត្តដោយផ្អែកលើភាពចាំបាច់ (Relevance) ប្រសិទ្ធភាព (Efficiency) ប្រសិទ្ធផល (Effectiveness) ចីរភាព (Sustainability) និងផលប៉ះពាល់ (Impact)
- ការវាយតម្លៃពាក់កណ្តាលអាណត្តិ (Mid-term Review)៖ នៅឆ្នាំ២០២៨
- ការវាយតម្លៃចុងក្រោយ (Final Evaluation)៖ នៅឆ្នាំ២០៣០
- ការវាយតម្លៃដោយឯករាជ្យ៖ ប្រើប្រាស់វិធីសាស្ត្រចម្រុះ (បរិមាណនិងគុណភាព) រួមមាន ការសម្ភាសន៍ ការវិភាគទិន្នន័យ និងករណីសិក្សា។

## ៩. សន្និដ្ឋាន

នយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បាននាំមកនូវសុខសន្តិភាព ឯកភាពជាតិ និងបូរណភាពទឹកដី ជូនប្រទេសកម្ពុជាក្នុងរយៈពេល២៥ឆ្នាំកន្លងមកនេះ។ ប្រការនេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជា អនុវត្តបានជោគជ័យនូវយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំងបួនដំណាក់កាល ដែលនាំឱ្យសម្រេចបាននូវសមិទ្ធផលជាច្រើនក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ជោគជ័យទាំងនេះបានធ្វើឱ្យកម្ពុជាទទួលបានកិត្តិយស កិត្យានុភាព និងការទទួលស្គាល់ពីអន្តរជាតិ។

ការកសាងសមិទ្ធផលទាំងនេះ វិស័យបរិស្ថាននៅតែបន្តជាអាទិភាពក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា សម្រាប់ការកសាង និងការពារ

មាតុភូមិ (២០២៣-២០២៨)។ យុទ្ធសាស្ត្របញ្ចកោណ មានគោលបំណងធានានូវកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព។ ទាំងនេះនឹងជាមូលដ្ឋានគ្រឹះ ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់ប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០៥០ ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងបរិបទនេះ ក្រសួងបរិស្ថាន ក្នុងនាមជាស្ថាប័នរដ្ឋាភិបាលនៃរាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨ ជាផែនទីបង្ហាញផ្លូវសម្រាប់វិស័យបរិស្ថានសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។ លើសពីនេះ យុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា ឆ្នាំ២០២៦-២០៣០ ត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ លើកកម្ពស់ការអភិរក្សជីវៈចម្រុះ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើបញ្ហាបរិស្ថាន។ ប្រការនេះពាក់ព័ន្ធនឹងការធ្វើការជាមួយប្រទេសផ្សេងទៀត ដើម្បីដោះស្រាយបញ្ហាប្រឈមជាសាកល និងលើកកម្ពស់ការប្រើប្រាស់ប្រកបដោយចីរភាពនៃធនធានធម្មជាតិ រួមទាំងព្រៃឈើ ទឹក និងដី តាមរយៈគោលនយោបាយ និងការអនុវត្តដែលធានាបាននូវបូរណភាពបរិស្ថានរយៈពេលវែង។

តាមរយៈការអនុវត្តនូវយុទ្ធសាស្ត្រការទូតបរិស្ថានកម្ពុជា កម្ពុជាសង្ឃឹមថានឹងជំរុញការថែរក្សាប្រព័ន្ធអេកូឡូស៊ី កិច្ចការពារបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព សំដៅឆ្ពោះទៅជាប្រទេសអព្យាក្រឹតកាបូននៅឆ្នាំ២០៥០ ខណៈពេលដែលរក្សាបាននូវភាពជាម្ចាស់ ឯករាជ្យ និងអធិបតេយ្យភាពរបស់ប្រទេសជាតិ៕